PRIMERICA
A Citi Company
Chanthy Sek &
Shawn Dougherty
Bus: 1-866-582-3172
Cell: 267-984-8554
- Life Insurance ធានារ៉ាប់រងជីវិត
- Car Insurance ធានារ៉ាប់រងរថយន្ត
- Refinance Your Debts រៀបចំសងប្រាក់ជំពាក់ឡើងវិញ
- Investments វិនិយោគទុន
- Office or Home Appointment. ជួបនៅការិយាល័យយើង ឬនៅផ្ទះលោកអ្នកក៏បាន
We also provide translation and interpretation services.
យើងផ្ដល់ការបកប្រែភាសា តាមច្បាប់ និងផ្ទាល់មាត់
E-mail: 8665823172@primerica.gosolo.com
Primerica Financial Services. 1035 Virginia Dr., Ste 100H. Ft. Washington, Pa 19034

# ខ្មែរប៉ុស្ដិ៍ The Khmer Post

ISSUE 32 13th-26th March 2009

ហាងមាសរស្មី
SUNSHINE JEWELRY INC
•Fine Jewelry
•Certified Diamonds & Custom Design
មានលក់គ្រឿង អលង្ការ យ៉ាងប្រណិតបំផុត ចេញសញ្ញាបត្រលើពេជ្រអាច ធ្លាក់ ឬ ថ្លៃ មាស ប្រាក់ ពេជ្រ ជូនបានតាមបំណង ។
យើងមានបទពិសោធន៍ ១៥ឆ្នាំ ហើយមានកេរ្តិ៍ឈ្មោះល្អក្នុងការបំរើសេវាអលង្ការនេះ
702 Washington Avenue
Philadelphia, Pa 19147
Phone: (215) 271-2950
Fax: (215) 271-2962
Email: colorofsunshine@yahoo.com

## រាត្រីសមោសរនាឱកាសបុណ្យចំរើនព្រះជន្មព្រះមហាក្សត្រ



•••ដើម្បីប្រមូលកុសលជាប្រយោជន៍ដល់សកម្មភាពសង្គម និងវប្បធម៌របស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថនរោត្ដម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា (តនៅទំព័រទី១១)

## Stimulus ទប់ស្កាត់វិបត្តិរបស់សហរដ្ឋអាមេរិក

ដោយ : ពិន សំខុន



•••នៅដើមអាណត្តិរបស់ប្រធានាធិបតីសហរដ្ឋអាមេរិក ស្បែកខ្មៅដំបូងគេបង្អស់ បារ៉ាក់ អូបាម៉ា ស្ថានភាពសេដ្ឋកិច្ចបានធ្លាក់ដាប រហូតត្រូវស្ដារឡើងដោយមធ្យោបាយដែលពុំដែលមានពី ៣០ឆ្នាំមុនមក ។ ប្រាក់ជាប្រមាណ ១ពាន់ប៊ីលីយ៉ុងដុល្លារ ឈ្មោះ Stimulus ត្រូវបានអនុញ្ញាតិឱ្យចាយ ដើម្បីសង្គ្រោះវិបត្តិដ៏ធ្ងន់ធ្ងររបស់សហរដ្ឋអាមេរិក។

នាឱកាសនេះ ការងារពលកម្មត្រូវបានចុះថយចំនួនកន្លះលានការងារក្នុងមួយខែ ។ ផ្ទះសម្បែងប្រមាណ ២លានផ្ទះ ត្រូវបានរឹបអូសយកទៅឱ្យគេវិញ, រោងចក្រធំៗ ត្រូវបានបិទទ្វារជាបន្តបន្ទាប់, រថយន្តថ្មី ដែលធ្វើហើយលក់មិនដាច់ មិនត្រឹមតែរោងចក្រប៉ុណ្ណោះទេ ទោះជាធនាគារធំៗខ្លះក៏រលំបះជើងរួចទៅហើយ ។ (តនៅទំព័រទី១១)



## ខ្មែរហ៊ើឡាចូលថតកុនហូលីវូតរឿង "THE LAST AIRBENDER"

ខ្មែរប៉ុស្ដិ៍, ដោយ : ពិន សំខុន

•••សមាជិកសមាគមន៍ខ្មែរ ៦នាក់ បន្ទាប់ពីបានដំណឹងថា មានការជ្រើសរើសអ្នកសំដែងតួក្នុងខ្សែភាពយន្តរបស់ផលិតកម្ម PARAMOUNT PICTURE ( តនៅទំព័រទី១៩ )

Mobile-net
We connect you to the world!
Since 1995
7.5¢
កម្ពុជា
ចុះឈ្មោះថ្ងៃនេះ នឹងទទួលបាន 133 នាទី សំរាប់ទូរស័ព្ទទៅកម្ពុជា ដោយឥតយកកំរៃ !
1.9¢ ថៃឡង់
5.5¢ ឡាវ
សេវាទូរស័ព្ទអន្តរជាតិដ៏ប្រសើរបំផុត
រកភ្នាក់ងារធ្វើការ
គ្មានកាលកំណត់
គ្មានយកកំរៃលើការតភ្ជាប់ប្រព័ន្ធ
គ្មានយកកំរៃលើការថែទាំ
គ្មានតម្លៃប្រែប្រួល
my011.com
1(800) 818-9000

ភោជនីយដ្ឋាន
បើកថ្មី!!!
Phở 486
Grand Opening
320 W. Oregon Avenue. Suite 1. Philadelphia, Pa 19148
Tel. 215-952-6688
Open: 7 days a week. Sunday – Thursday: 9 a.m. – 9 p.m.
Friday & Saturday: 9 a.m. – 10 p.m.
បើកទទួលភ្ញៀវរៀងរាល់ថ្ងៃចាប់ពីម៉ោង ៩ ព្រឹក ដល់ម៉ោង ៩ យប់
លើកលែងតែថ្ងៃសុក្រ និងសៅរ៍ បើករហូតដល់ ១០ យប់
•យើងមានមុខម្ហូបសំរាប់ពិសារបាយ មាន គុយទាវ មាននំបញ្ចុក ហើយជាពិសេសមានធ្វើ "ហ្វឺ" គ្រប់មុខ ជូនពិសារយ៉ាងឈ្ងុយឆ្ងាញ់
•បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែររងចាំបំរើអតិថិជនមិនឱ្យខុសបំណងឡើយ

# សកម្មភាពនៅហ្វីឡាដែលហ្វីយ៉ា

**I. "សមាគមព្រឹទ្ធាចារ្យខ្មែរ"** ត្រៀមនឹងបើកពិធីជប់លៀងចូលឆ្នាំខ្មែររបស់ខ្លួន នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង៧យប់ នៅភោជនីដ្ឋាន " សាយ គួនម៉ាកសិុម " ផ្លូវ វ៉ាសុិនតុន ហ្វីឡាខាងត្បូង ដោយមានក្រុមតន្ត្រីសម័យកំដរពេញមួយរាត្រីនោះផង ។

សាធារណជនអាចចូលរួមអបអរសាទរពិធីជប់លៀង ប្រចាំឆ្នាំរបស់សមាគមព្រឹទ្ធាចារ្យបាន ដោយទាក់ទងទៅ ទូរស័ព្ទលេខ 215-218 0585 តម្លៃសំបុត្រ $40.

**II. សមាគមខ្មែរនៅហ្វីឡាដែលហ្វីយ៉ា** នឹងរៀបចំទទួលពិធីចូលឆ្នាំឆ្នូវ នៅថ្ងៃទី១១ មេសា ឆ្នាំ២០០៩ វេលាម៉ោង ៧ល្ងាច នៅសណ្ឋាគារ "ហីលតុន" 4200 City Avenue. Philadelphia. ចូលរួមកំសាន្តដោយក្រុមតន្ត្រីសម័យ និងកម្មវិធីបង្ហាញវប្បធម៌ខ្មែរជាច្រើនទៀត ។

បើលោកអ្នកចង់ចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំ ជាមួយនឹងសមាគមខ្មែរនាថ្ងៃទី១១ មេសានោះ តម្លៃសំបុត្រ $50 ដោយសូមអញ្ជើញទាក់ទងទៅ **215-324 4070** ។

**III. មូលនិធិខ្មែរសម្រាប់ការសិក្សា**

**C.E.E Foundation**

ដឹកនាំដោយលោកវេជ្ជបណ្ឌិត ខ្មៅ សំរ៉ង C.E.E Foundation បានបើកពិធីជប់លៀងមួយនារាត្រីថ្ងៃសៅរ៍ ទី៧ មិនា ឆ្នាំ២០០៩ ម៉ោង៧យប់ នៅហ្វីឡាដេលហ្វីយ៉ា ខាងជើង ដើម្បីស្វែងរកកម្រៃជួយដល់កុមារខ្មែរ ។




រាត្រីថ្ងៃទី៧នេះ ភ្ញៀវប្រមាណ ៣០០នាក់ បានរីករាយរាំកំសាន្ត ហើយបានផ្តល់វិភាគទានជួយបង្កើតសាលារៀនកុំព្យូទ័រមួយ សម្រាប់ដាក់នៅសកលវិទ្យាល័យបច្ចេកទេសឱ្យយុវជនខ្មែររៀននៅកម្ពុជា ។

ឆ្នាំកន្លងទៅហើយនេះ C.E.E Foundation ជួយបានអាហារូបករណ៍ចែកដល់សិស្សានុសិស្សប្រមាណ ១២៥នាក់ដោយមានទាំងព្រះសង្ឃផងរួចហើយ ។

**IV. អតីតយុទ្ធជនខ្មែរ** នៅហ្វីឡាដែលហ្វីយ៉ា កំពុងធ្វើសកម្មភាពឆ្លងរដ្ឋ យ៉ាងគួរឱ្យចាប់អារម្មណ៍ ។ កិច្ចប្រជុំដែលមានអតីតយុទ្ធជនប្រមាណ ៤០នាក់ចូលរួម (តទៅទំព័រទី០៩)


# ការិយាល័យច្បាប់របស់ ជេហ្វ្រី អិន ខែល



Law Offices of
Jeffrey N. Kale
Attorney at Law



ពិគ្រោះករណីច្បាប់ដោយមិនគិតកំរៃ យើងបានបំរើសេវាច្បាប់ជូនដល់សហគមន៍ខ្មែរជាង២០ឆ្នាំហើយ .ការិយាល័យ "ច្បាប់ទូទៅ" ដែលមានជំនាញផ្លូវច្បាប់ដូចតទៅ:

- គ្រោះថ្នាក់រថយន្ត
- បើកបរក្រោមឥទ្ធិពលស្រវឹង ឬពុល
- មានរបួសនៅកន្លែងធ្វើការ
- ទិញលក់អចលនវត្ថុ
- ច្បាប់បើកក្រុមហ៊ុន
- ច្បាប់ឧក្រិដ្ឋកម្ម
- គ្រោះថ្នាក់ដោយរអិល ឬដួល
- រំលោភច្បាប់លើផ្លូវចរាចរ
- ការទារឱ្យសងប្រាក់ជំពាក់ ។ល។

**New Jersey : 856-216-7171**
**1236 Brace Road, Suite K, Cherry Hill, NJ 08034**
**Pennsylvania/Philadelphia: 215-564-6900**
**1700 Sansom St., 3rd Floor, Street, Philadelphia, PA 19103**

**FREE CONSULTATIONS**
Providing legal services to the Cambodian community for 20 years
General Law Office specializing in the following areas of law:

| | |
|---|---|
| Car Accidents | Criminal Law |
| DUI/DWI | Slip & Fall Accidents |
| Workplace Injury | Traffic Violations |
| Real Estate | Collections |
| Corporate Law | |

សេវាច្បាប់ប្រកបដោយវិជ្ជាជីវៈ នឹងតម្លៃសមរម្យអាចមានអ្នកបកប្រែជូនបាន





# ADAMS DENTAL CENTER

801 ADAMS AVENUE. PHILADELPHIA, PA 19124. TEL: 215-744-8300





សូមអញ្ជើញមកមជ្ឈមណ្ឌលធ្វើធ្មេញ "អាដាម" យើងធ្វើចុនពីដើមដល់ចប់បានយើងមានក្រុមទន្តបណ្ឌិត៤រូប ដែលមានជំនាញគ្រប់ផ្នែកក្រោយនៃវិជ្ជាធ្វើធ្មេញ ។

មណ្ឌលធ្មេញឯកទេស ខាងការងារលំអរ

**ឯកទេសខាង**

- ✓ Crowns,
- ✓ Braces,
- ✓ Bridges,
- ✓ Veneers,
- ✓ Inlay,
- ✓ Gold Caps,
- ✓ Implants,
- ✓ Full & Partial Dentures.

យើងជាមជ្ឈមណ្ឌលនៅហ្វីឡាដែលហ្វៀតែមួយដែលមានបន្ទប់ពិសោធន៍ នៅជាមួយគ្នានេះទីនោះ លោក-អ្នកអាចប្តូរធ្មេញជំនួសដែលផលិតឡើងតាមគុណភាពដែលលោកអ្នកចង់បានទាំងអស់ សុទ្ធតែដំណើរការដោយបច្ចេកទេសវិជ្ជាជាន់ខ្ពស់ ហើយប្រើលំនាំប្រព័ន្ធ OSHA ជាក្បួន។

**ទន្តសាស្ត្រទូទៅ**

- ដកធ្មេញ
- បំពេញធ្មេញប្រហោង
- ព្យាបាលប្រហោងដល់ឫសធ្មេញ
- ផ្ចិតចន្លោះធ្មេញមុខ-ធ្មេញបាក់ ធ្មេញស្រោម ឬធ្មេញដង្កូវស៊ី
- **សំអាតធ្មេញឱ្យស្អាត:** ដោយធ្វើដោយឡេស៊ែរមួយម៉ោង ឬយកប្រដាប់ទៅសំអាតនៅផ្ទះ
- យើងក៏មានធ្វើការសំអាតដោយ "អុលត្រាសោន" ដែលធ្វើមិនឱ្យយើងឈឺ

**បើកមជ្ឈមណ្ឌល**

ថ្ងៃ ច័ន្ទ : 10am-6pm
ថ្ងៃ អង្គារ : 10am-6pm
ថ្ងៃ ពុធ : 10am-7pm.
ថ្ងៃ ព្រហស្បតិ៍ : 10am-6pm
ថ្ងៃ សុក្រ : 10am-6pm.
ថ្ងៃ សៅរ៍ : 10am-7pm

**យើងទទួលយកផែនការណ៍ជួយធ្វើធ្មេញស្ទើរតែទាំងអស់**

Cigna Dental, 1201 Dental Plan, Delta Dental, DHA, Guardian,Aetna,PPO, Ameri-Health, United Concordia Flex, MetLife, Unicare.

ចុះថ្លៃ 10% ដល់អ្នកគ្មានប័ណ្ណសុខភាព

អាចធ្វើផែនការណ៍ចេញថ្លៃរាល់ខែ

# អំណាចឈរ អំណាចដេកនៅកម្ពុជា

**ខ្មែរប៉ុស្តិ៍ , ដោយ : ពិន សំខុន**

●●●អំណាចនយោបាយដែល "ឈរ" មានលំនឹង គឺជាអំណាចដែលសាធារណជនទទួលយកបាន ក្នុងទំហំភាគច្រើន ហើយជាពិសេស គឺភ្ជាប់ទៅនឹងសកម្មភាពសីលធម៌ ។ រីឯអំណាចនយោបាយ "ដេក" គឺជាអំណាចក្នុងអវិជ្ជា បានដោយការកេងប្រវ័ញ្ច បង្ខិតបង្ខំ ហើយប្រាសចាកសីលធម៌ ។ នៅកម្ពុជា នា១០ឆ្នាំចុងក្រោយនេះ អំណាចនយោបាយត្រូវបានគេខិតខំបញ្ឈរនូវអំណាចដែលកំពុងតែដេកលក់យ៉ាងជ្រាលជ្រៅ ប្រឹងទាំងថ្ងៃ ប្រឹងទាំងយប់ ប្រើថាមពលខ្លួនឯងផង ប្រើថាមពលបរទេសផង ប្រើស្បៀតបែបងឹតគ្រប់យ៉ាង ឱ្យតែបានអំណាចនយោបាយនោះ នៅមានរូបភាព "ឈរ" បាន ។

កាលពី " ខ្មែរប៉ុស្តិ៍ " លេខមុន យើងបានលើកពីករណីដក "អគ្គមេបញ្ជាការជាន់ខ្ពស់នៃកងទ័ព កែ គឹមយ៉ាន ហើយមានការចាប់ខ្លួនឧត្តមសេនីយរូបនោះថែមទៀត ក្រោមការបញ្ជារបស់នាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ។ ករណីនេះសម្រាប់អ្នកតាមដាននូវស្ថានភាពនយោបាយនៅកម្ពុជា គេពុំមានការភ្ញាក់ផ្អើលអ្វីប៉ុន្មានទេ ដោយសារតែការផ្លាស់ប្តូរនេះស្ថិតនៅលើរូបភាពខាងក្រៅ រីឯមូលដ្ឋាននៃការពង្រឹងអំណាចនយោបាយពុំទាន់មានអ្វីផ្លាស់ប្តូរនៅឡើយទេ ។

រូបភាពខាងក្រៅ គឺលោក កែ គឹមយ៉ាន ជាមន្ត្រីដែលនៅក្នុងចរន្តគណបក្សប្រជាជន ស្លាបមេបក្ស ជា ស៊ីម ដែលកំពុងខិតខំឱ្យទប់ទល់កុំឱ្យចរន្តបក្សប្រជាជន ហ៊ុន សែន ចេះតែឈ្នះជារហូតទៅកើត ដូច្នេះការដកតួនាទីលោកមេបញ្ជាការ កែ គឹមយ៉ាន គឺជាការចាំបាច់រង់ចាំតែពេលវេលាតែប៉ុណ្ណោះ ។

រូបភាពជាមូលដ្ឋាន គឺលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានការគាំទ្រយ៉ាងរឹងមាំពីប្រទេសវៀតណាម បន្ទាប់មកពីប្រទេសចិន ដែលប្រើព្រះបរមរាជវាំងខ្មែរឱ្យធ្វើតាមបំណងលោក ហ៊ុន សែន ដោយគ្មានលក្ខខ័ណ្ឌម្តងណាឡើយ ។ គឺនៅលើមូលដ្ឋានចុងក្រោយនេះហើយ នៅពេលដែលលោកមេប៉ូលិស ហុក ឡង់ឌី ជាភ្នែកច្រមុះនៃវៀតណាម បានទទួលគ្រោះថ្នាក់ដល់ជីវិតទៅ ក៏បានជម្រុញឱ្យស្ថានការណ៍ប្រឹងដើរយ៉ាងលឿន ដក កែ គឹមយ៉ាន ឱ្យបានជាប្រញាប់ ពង្រឹងដោយមនុស្សជំនិតរបស់ខ្លួន ដូចជា ឧត្តមសេនីយ ប៉ុល សារឿន, ឧត្តមសេនីយ៍ គន់ គីម, ឧត្តមសេនីយក្មួយ និងឧត្តមសេនីយកូនបង្កើតភ្លាមៗដែរ ។

តើសកម្មភាពនេះ អាចហៅថា ជាអំណាចនយោបាយ "ឈរ" បានដែរឬទេ ? ទាំងលោក ហ៊ុន សែន ទាំងលោក ជា ស៊ីម នាំគ្នាត្រៀមឈរនៅលើផ្លូវកុម្មុយនិស្តផ្តាច់ការនិយម ក្នុងការគ្រប់គ្រប់របស់វៀតណាម ។ អ្នកទាំងពីរបើទោះជាខាងណាឈ្នះ គឺគ្រាន់តែជាការដណ្តើមឈ្នះនៅក្នុងបក្សរបស់ខ្លួនតែប៉ុណ្ណោះ ។ នាឱកាសនេះ មហាប្រទេសចិន និងយៀកណាម ពុំមានឃើញប្រយោជន៍ណាមួយនឹងប្តូរលោក ហ៊ុន សែន ឱ្យចេញពីអំណាចនយោបាយខ្មែរសោះនៅឡើយ ហើយអ្នកដែលត្រូវមកជំនួយនាយករដ្ឋមន្ត្រីរូបនោះ ក៏ពុំទាន់ឱ្យមានការចាប់អារម្មណ៍ទៅលើវរៈជនគណបក្សប្រជាជនណាមួយ នៅឡើយដែរ ។

ប្រទេសកម្ពុជាតាំងតែពីបានរំដោះខ្លួនចេញពីអនានិគមបារាំងរួចមកហាក់ចូលទៅក្នុងទឹកនៃរបបកុម្មុយនិស្តចិន ចាប់តាំងពីឆ្នាំ ១៩៦០មក ។ មកដល់ឆ្នាំ ១៩៦៥ តាមការណែនាំរបស់ចិន ក៏ចុះហត្ថលេខាជួយសង្គ្រាមយៀកណាមខាងជើងឱ្យវាយយៀកណាមខាងត្បូង បណ្តាលឱ្យកម្ពុជាធ្លាក់ក្នុងភ្លើងសង្គ្រាម រវាងកុម្មុយនិស្តនិងលោកសេរីយ៉ាងធ្ងន់ធ្ងរ ។ ឆ្នាំ ១៩៧៥ របបកុម្មុយនិស្តបានទទួលជ័យជំនះមួយហើយមួយទៀត ខ្មែរប្រមាណជាពីរលាននាក់ បានបាត់បង់ជីវិត ដោយគ្មានភ្លើងបូជាសព ។ នយោបាយ "ដេក" បានបង្ហាញខ្លួនយ៉ាងច្បាស់ចាប់តាំងពីឆ្នាំ ១៩៦៥ មក ។

រូបភាពដ៏អណោចអធមនៃអំណាច "ដេក" នៅកម្ពុជា ត្រូវបានអង្គការសហប្រជាជាតិ លូកដៃមកធ្វើឱ្យ "ឈរ" វិញ នាឆ្នាំ ១៩៩១ ហើយឆ្នាំ ១៩៩៣ ការបោះឆ្នោតជាសកលបានធ្វើឱ្យរាស្ត្រខ្មែរ មានសិទ្ធិធ្វើការសម្រេចចិត្តជាដំបូងបង្អស់ បន្ទាប់ពីបាត់បង់សិទ្ធិនោះអស់ពេលដ៏យូរ ... ក៏ប៉ុន្តែគួរឱ្យអនិច្ចារ... សេចក្តីសម្រេចចិត្តរបស់រាស្ត្រត្រូវបានសម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋបោះបង់ចោល ហើយយកសេចក្តីសម្រេចចិត្តរបស់ព្រះអង្គ គឺគ្មានអ្នកចាញ់ គ្មានអ្នកឈ្នះ ដែលបានធ្វើឱ្យគណបក្សដែលគ្មានបង្អែកជាមួយប្រទេសមហាអំណាច ត្រូវរងគ្រោះគ្រប់បែបយ៉ាង រហូតមកដល់សព្វថ្ងៃនេះ ក្នុងរូបភាពអំណាច "បញ្ឈរ" យ៉ាងសកម្ម ។

នៅមានស្ថានការណ៍បីដែរ ដែលកំពុងតស៊ូយ៉ាងស្វិតស្វាញ ដើម្បីឱ្យកម្ពុជា អាចក្រោកដោយមិនបាច់ប្រឹង គឺអង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិ , បក្សប្រឆាំងខ្មែរ និងតុលាការអន្តរជាតិ ដែលគេត្រូវតាមដានថា តើអាចទប់ទល់នឹងកលល្បិចអំណាចនយោបាយ "ដេក" បានយូរដល់ប៉ុណ្ណានោះ ។

ពត៌មានចុងក្រោយនាដើមខែមីនានេះ និយាយថា លោក កែ គឹមយ៉ាន អាចនឹងត្រូវតែងតាំងជាឧបនាយករដ្ឋមន្ត្រី នាពេលឆាប់ៗនេះ ។ ពត៌មាននេះ ពុំបានធ្វើឱ្យការវិភាគនយោបាយរបស់ខ្ញុំផ្លាស់ប្តូរអ្វីនោះទេ ពីព្រោះបើទោះបីលោក កែ គឹមយ៉ាន បានក្លាយទៅជាឧបនាយករដ្ឋមន្ត្រីខ្មែរមែនពិតក៏ដោយក្តី ក៏តួនាទីនេះ បានត្រឹមតែតួនាទីកិត្តិយសតែប៉ុណ្ណោះ ពុំមានអំណាចទប់ទល់នឹងនរណាមួយបានឡើយ ។ នៅកម្ពុជាមន្ត្រីកិត្តិយស សំរាប់លំអទីក្រុងមានច្រើនរូបណាស់ ដោយរាប់តាំងពីរាជ-វង្សានុវង្ស រហូតដល់បក្សប្រជាជនស្លាប ជា ស៊ីម ផងដែរ ៕

**ពិន សំខុន**


# BALDI FUNERAL HOME

## 1331 S. Broad St. Philadelphia, Pa 19147

## Cell: 267-934-9888 / Tel : 215-389-2414

**សូមសួរអកលោក សេខ ឬ Thomas**

**ឈាបណកិច្ចតាមប្រពៃណី**

ឈាបណដ្ឋានមានផ្តល់ជូននូវក្តារមឈូស ទីធ្លាសំរាប់បញ្ចុះ រៀបកំរងផ្កា និងសេវាឈាបណកិច្ចច្រើនប្រភេទ តម្លៃទៅតាមប្រភេទដែលត្រូវការសេវាឈាបណកិច្ចតាមវប្បធម៌ និងតាមសាសនា និងបំពេញជូនជាកិត្តិយស យើងនឹងខំឱ្យអស់ពីសមត្ថភាព ដើម្បីបំពេញសេចក្តីត្រូវការ និងបំពេញប្រាថ្នារបស់លោកអ្នក ។

**ពិធីបូជាសព**

"បាល់ឌី" ផ្តល់ជូននូវពិធីបូជាសពគ្រប់បែបជម្រើសរាប់ទាំងឱ្យភ្លើង ក្តារមឈូសសំរាប់សពទន្ទឹមនោះមានសេវាពិធីបុណ្យតាមវប្បធម៌ ការតម្កល់អដ្ឋិ-ធាតុជាចុងបញ្ចប់ ។ មានជួយធ្វើលិខិតក្នុងករណីចង់នាំអដ្ឋិធាតុទៅកាន់ប្រទេសមួយទៀត មានចារឈ្មោះសពនៅលើទំព័រ "ខ្មែរប៉ុស្តិ៍" ជូនផង ។





**(Locates in South Philly, convenience traffic, and free parking)**

**Traditional Funeral**

Funeral Home provides caskets, cemetery space, floral arrangements, and funeral service options in various price ranges. Cultural and Religious funeral service is honored. We put full efforts to meet your needs and fulfill your wishes.

**Cremation**

Baldi offers complete cremation options including a combustible casket for the body, on site performing cultural memorial service, final placement of the cremated remains, paperwork assistance in case that need to transport the cremated remains to another country, and the Khmer Post newspaper notices.

# បទពិសោធន៍ជួយឱ្យយុវជនមានអនាគតល្អ

*ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ឃុត សីហា*

•••មានការព្យាយាមប្រឹងប្រែងស្វែងយល់កាន់តែច្រើនពីសំណាក់យុវជននៅតាមអង្គការ ឬសមាគម ដោយពួកគេយល់ថា ដើម្បីក្លាយខ្លួនជាកម្លាំងការងាររបស់សង្គមបាននោះលុះត្រាតែស្វែងយល់បទពិសោធន៍តាមរយៈសមាគម និងស្វែងយល់ពីបរិស្ថានការងារនៅជុំវិញខ្លួនជាមុនសិន។

ជុំវិញការបន្សាំខ្លួនចូលប្រឡូកក្នុងការងារសមាគមដោយស្ម័គ្រចិត្តនោះ មានយុវជនមួយចំនួនបានបញ្ចេញទស្សនៈយល់ឃើញថា វាគឺជាបទពិសោធន៍ដ៏ល្អមួយសម្រាប់កសាងខ្លួនទៅអនាគត។

កញ្ញា អ៊ុច សុវណ្ណាឡៃ អាយុ24ឆ្នាំ ជាបុគ្គលិកស្ម័គ្រចិត្តនៃសមាគមយុវជនខ្មែរ និងធ្លាប់បានទៅបោះជំរំនៅប្រទេសស៊ុយអ៊ែត បានបញ្ចេញទស្សនៈយល់ឃើញថា ប្រការដែលតម្រូវឱ្យយុវជនមានការផ្លាស់ប្តូរបទពិសោធន៍នៅតាមសហគមន៍ គឺប្រយោជន៍ដើម្បីស្វែងយល់ និងឈានទៅរកសង្គមការងារមួយដែលជាកត្តាសំខាន់បំផុតរបស់យុវជន។

កញ្ញាបន្តថា យុវជនម្នាក់ៗមានតម្លៃណាស់សម្រាប់គ្រួសារ និងសង្គមជាតិ ពិសេសជីវិតវប្បធម៌ទំនៀមទម្លាប់ខ្មែរ និងភាពហ្មឺងម៉ាត់ក្នុងការងាររបស់យុវជនខ្មែរ។

ចាប់តាំងពីឆ្នាំ 2002 រហូតមកដល់បច្ចុប្បន្ន សមាគមយុវជនខ្មែរបានបញ្ជូនយុវជនទៅធ្វើកម្មសិក្សាផ្លាស់ប្តូរបទពិសោធន៍ជាមួយក្រុមយុវជននៅប្រទេសស៊ុយអ៊ែតបានចំនួន 7 លើក និងមានយុវជនជាង100នាក់ហើយ ដែលបានទៅ។

ការទៅធ្វើការជួបជុំរវាងយុវជននេះ ត្រូវបានលោក ហ៊ឹម យន់ ប្រធានស្តីទីនៃសមាគមយុវជនខ្មែរប្រាប់ថា ក្នុងគោលបំណងដើម្បីឱ្យយុវជនខ្មែរបានផ្លាស់ប្តូរទំនៀមទម្លាប់ វប្បធម៌ និងរបៀបរបបធ្វើការងារក្នុងសហគមន៍នៃប្រទេសនីមួយៗ ហើយជាទំនោរទៅរកទំនើបភាវូបនីយកម្មផង។

លោកបញ្ជាក់ថា ក្រុមយុវជនទាំងនោះភាគច្រើនពួកគេបានចូលបម្រើការងារនៅតាមអង្គការសង្គមស៊ីវិល និងតាមស្ថាប័នផ្សេងៗ ហើយមានយុវជនខ្មែរខ្លះបានធ្វើការនៅអង្គការសហប្រជាជាតិផ្នែកកម្មវិធីយុវជនទៀតផង។ ក្រៅពីសមាគមយុវជនខ្មែរ អង្គការយុវសន្តិភាពដែលធ្វើការទៅលើក្រុមយុវជននោះ យុវជនដទៃៗទៀតនៅក្នុងអង្គការនេះក៏មានទស្សនៈយល់ឃើញដូចក្រុមយុវជនខាងលើដែរ។

យុវជន ហ៊ុយ សុធារិទ្ធ មានចំណាប់អារម្មណ៍ថា ការផ្លាស់ប្តូរបទពិសោធន៍រវាងយុវជនក្នុង និងក្រៅប្រទេស ឬយុវជនជាមួយមនុស្សចាស់ មានសារសំខាន់ណាស់ ។ ពេលយើងចុះតាមសហគមន៍ជួបជាមួយក្រុមយុវជន និងជាមួយមនុស្សចាស់នោះ មិនមែនយើងគ្រាន់តែផ្តល់បទពិសោធន៍ឱ្យពួកគាត់ទាំងស្រុងនោះទេ តែផ្ទុយទៅវិញ យើងក៏បានទទួលនូវបទពិសោធន៍ជាក់ស្តែងពីពួកគាត់ទៀតផង។

យុវជន ទូច សុភី និស្សិតផ្នែកចិត្តវិទ្យាឆ្នាំទី4 នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាយុវជនស្ម័គ្រចិត្តនៃអង្គការយុវសន្តិភាពបាននិយាយថា "បើតាមខ្ញុំយល់ការផ្លាស់ប្តូរបទពិសោធន៍ គឺជាវិធីមួយដ៏ល្អ ព្រោះបើយើងរស់នៅក្នុងសង្គមមួយមានចំណេះដឹងតែម្នាក់ឯង ដូច្នេះយើងមិនអាចសម្របខ្លួនជាមួយយុវជនផងគ្នាបានទេ ប្រសិនបើយើងគ្មានការចែករំលែកបទពិសោធន៍គ្នានោះ"។

( តទៅទំព័រទី១៨ )



យុវជនកម្ពុជា និងយុវជនស៊ុយអ៊ែត កំពុងពិភាក្សាផ្លាស់ប្តូរបទពិសោធន៍

ការចែករំលែកនូវបទពិសោធន៍រវាងយុវជន និងយុវជន ឬយុវជន និងមនុស្សជំនាន់មុន គឺជាការដុសខាត់ចិត្តគំនិតបានស្គាល់ច្បាស់ពីទម្លាប់អាក្រក់ និងទម្លាប់ល្អពីគ្នាទៅវិញទៅមក ។

របស់គេផ្ទាល់តែម្តងឱ្យតែយើងស្ម័គ្រចិត្តប្រឡូកក្នុងការងារសង្គម ដោយព្យាយាមតាមដានព័ត៌មានទាក់ទងនឹងសង្គម ។ តែទោះជាយ៉ាងណាកញ្ញាបានសង្កត់ធ្ងន់ថា មានយុវជនមួយភាគធំមិនសូវបានចូលរួមក្នុងសហគមន៍ប៉ុន្មានទេ ទាក់ទងនឹងការងារសង្គម ពិសេសបញ្ហានយោបាយ។

កញ្ញាបញ្ជាក់ថា "ពីមុនខ្ញុំក៏អ៊ីចឹងដែរ តែឥឡូវខ្ញុំមានការផ្លាស់ប្តូរចិត្តគំនិតច្រើន ពោលគឺព្យាយាមធ្វើយ៉ាងណាឱ្យតែខ្លួនបានជួយសង្គម ។ តាមរយៈការជួយជំរុញឱ្យយុវជនចូលរួមក្នុងវិស័យសង្គមក្នុងសិក្ខាសាលានៅតាមអង្គការ ព្រោះគេមានវិស័យច្រើនណាស់ទាក់ទងការងារសង្គម និងការកសាងសមត្ថភាពយុវជន" ។

កញ្ញា អ៊ុច សុវណ្ណាឡៃ ដែលធ្វើការក្នុងកម្មវិធីយុវជននៅអង្គការសហប្រជាជាតិ ដែលនាងតែងតែទៅចូលរួមនោះ បាននិយាយថា ចំពោះយុវជននៅស៊ុយអ៊ែតឱ្យតែមានអាយុ18ឆ្នាំឡើង ម្តាយឪពុកគេដេញឱ្យទៅរកការងារធ្វើហើយ ហើយការងារសម្បូរ ដូចជាគេធ្វើតាមឡាន់ប៉ុង តាមរោងចក្រ ធ្វើជាចុងភៅ ឬជាអ្នកមើលថែទាំមនុស្សចាស់ ដែលពួកគេអាចរកលុយបានច្រើនរហូតដល់សល់លុយចេញទៅដើរលេងក្រៅប្រទេសថែមទៀតផង។

កញ្ញាបានលើកសម្តីដៃគូរបស់នាងឈ្មោះ Tessan អាយុ24ឆ្នាំថា គាត់បានស្គាល់ពី

NEW GOLDEN PALACE RESTAURANT
801-21 Washington Ave.
Phone: 215-627-2822

Open Daily from 10am-10pm
Dim Sum Every Day from 10am - 3pm

Authentic Chinese & Vietnamese Cuisine
Very Delicious and Nutritious

-ហាងយើងមានម្ហូបចិន និងម្ហូបវៀតណាមពិតប្រាកដ មានរសជាតិឈ្ងុយឆ្ងាញ់ ហើយជីវជាតិប្រសើរ
**ពិសេសនៅពេលរាត្រី :** ចាប់ពីម៉ោង ៦ ល្ងាច ដល់បិតហាង ជូនភេសជ្ជៈពិសារដោយឥតគិតថ្លៃ (ពិសារយ៉ាងតិច **$20**)
**ពិសេសដោយម្ចាស់ហាង:** មានចុះតម្លៃ **10%** លើម្ហូបអាហារថ្ងៃត្រង់ ឬល្ងាច បើលោកអ្នកបង្ហាញប័ណ្ណពាណិជ្ជកម្មយើងដល់អ្នកគិតលុយ

**Nightly Special:** 6pm 'til Closing: FREE drinks with every meal ($20 minimum order)
**Manager Special:**
Take 10% off meal (Lunch & Dinner) when your present this advertisement

Manager Special :
-10% OFF
LUNCH & DINNER
Present This Coupon



# អាមេរិកផ្តល់លុយ20លានដុល្លារ

ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល



លោកស្រី Carol A Rodley ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក

•••ពីមួយឆ្នាំទៅមួយឆ្នាំប្រទេសអ្នកផ្តល់អំណោយទានដល់កម្ពុជា បានធ្វើការបរិច្ចាគលុយកាក់ឱ្យកាន់តែច្រើន ដើម្បីឱ្យរដ្ឋាភិបាលធ្វើការអភិវឌ្ឍន៍ប្រទេសជាតិ ហើយពួកគេមិនសូវបានធ្វើការតាមដានពីលទ្ធផល និងសកម្មភាពរបស់រដ្ឋាភិបាល ហ៊ុន សែន នោះទេ ។

ដោយឡែកកាលពីពេលថ្មីៗនេះស្ថានទូតអាមេរិកបានផ្តល់លុយប្រមាណ20លានដុល្លារសំរាប់គំរោងអភិវឌ្ឍន៍រយៈពេល5ឆ្នាំ ដើម្បីពង្រឹងនូវតម្លាភាពប្រព័ន្ធតុលាការ និងផ្នែកសិទ្ធិមនុស្សឱ្យប្រសើរឡើង ដោយរួមទាំងរដ្ឋាភិបាលសង្គមស៊ីវិល និងផ្នែកឯកជនផងដែរ ។

លោកស្រី Carol A Rodley ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជាបានមានប្រសាសន៍ថា យើងមានជំនឿថា គម្រោងនឹងរាប់បញ្ចូលជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើកំណែទម្រង់ច្បាប់ និងជំរុញផ្នែកសិទ្ធិមនុស្សនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង ។

លោកស្រី Carol A Rodley បន្តថា តាមរយៈជំនួយដ៏សែនសន្ធឹកសន្ធាប់នេះយើងសង្ឃឹមថា អាមេរិកនឹងបន្តការងារទាំងនេះជាមួយកម្ពុជាឱ្យមានការរីកចម្រើនជាងមុនទាំងប្រព័ន្ធច្បាប់ និងសិទ្ធិមនុស្ស ។

កន្លងមកតាមរយៈកម្មវិធីអភិវឌ្ឍន៍អន្តរជាតិ (USAID) បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីតុលាការ មេធាវី នៅសាលាដំបូងដើម្បីជួយការពារក្តីឱ្យជនរងគ្រោះបានមួយចំនួនផងដែរ ។ ប៉ុន្តែទោះបីជាយ៉ាងណាប្រព័ន្ធតុលាការនៅតែពុំទាន់មានតុល្យភាពបម្រើប្រយោជន៍ប្រជាពលរដ្ឋក្រីក្រនោះទេ ។

ទាក់ទងទៅនឹងកំណែទម្រង់ប្រព័ន្ធតុលាការ និងសិទ្ធិមនុស្សត្រូវបានគណបក្សប្រឆាំង និងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ សំដែងការគាំទ្រ ព្រមទាំងបានស្នើសុំទៅរដ្ឋាភិបាលឱ្យកែប្រែជាបន្ទាន់ ដើម្បីព្យាបាលជំងឺសង្គមឱ្យជាសះស្បើយបានឆាប់បំផុត ។

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី បានធ្វើការរិះគន់ចំពោះរដ្ឋាភិបាលមិនសំចៃមាត់ថា អំពើពុករលួយប្រព្រឹត្តផ្តេសផ្តាស់ធ្វើឱ្យប្រជាជនរងទុក្ខលំបាកវេទនាគ្រប់ទីកន្លែង ហើយតុលាការបានក្លាយជាឈ្នាន់របស់អ្នកកាន់អំណាច ដើម្បីគាបសង្កត់មន្ត្រីគណបក្សប្រឆាំង និងប្រជាពលរដ្ឋស្លូតត្រង់ទៀតផង ។

លោក សម រង្ស៊ី ធ្លាប់បានស្នើរទៅប្រទេសអ្នកផ្តល់ជំនួយឱ្យដាក់លក្ខខណ្ឌដល់រដ្ឋាភិបាលកម្ពុជាមុនពេលផ្តល់លុយកាក់ដល់នាយករដ្ឋមន្ត្រី ហ៊ុន សែន ប៉ុន្តែរាល់ការស្នើរសុំរបស់លោកត្រូវប្រទេសអ្នកផ្តល់អំណោយទានមិនចាប់អារម្មណ៍ទៅវិញ ។ ជាពិសេសនៅឆ្នាំ2008កន្លងមកនេះប្រទេសទាំងនោះបានផ្តល់លុយប្រមាណជិត1000លានដុល្លារឱ្យកម្ពុជា ដែលច្រើនជាងរាល់លើកជិត2ដងឯណោះ ។

យោងតាមរបាយការណ៍របស់អង្គការអន្តរជាតិបានញ្ជាក់ឱ្យដឹងថា រដ្ឋាភិបាលកម្ពុជាបានជំរុញឱ្យតុលាការដាក់សម្ពាធទៅលើគណបក្សប្រឆាំង និងប្រជាពលរដ្ឋស្លូតត្រង់ជាបន្តបន្ទាប់គួរឱ្យភ័យខ្លាចខ្លាំងណាស់ ។ ជាក់ស្តែងលោក សម រង្ស៊ី ត្រូវតុលាការចោទប្រកាន់ពីបទបរិហាកេរ្តិ៍សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ឆ្នាំ2005 លោក កឹម សុខា ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្ស លោក ម៉ម សូណង់ដូ ប្រធានស្ថានីយ៍វិទ្យុសំបុកឃ្មុំ ពីបទផ្សព្វផ្សាយព័ត៌មានលោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀន ឯករាជ្យកម្ពុជា ដែលរិះគន់រដ្ឋាភិបាលរឿងព្រំដែន ក៏ត្រូវចាប់ដាក់គុកដែរ ។

ដោយសារតែប្រព័ន្ធតុលាការមិនយុត្តិធម៌ និងមិនគួរឱ្យជឿទុកចិត្តបាននោះ ប្រជាជនជាច្រើនបានលើកគ្នាទៅតវ៉ានៅមុខរដ្ឋសភាឱ្យអ្នកតំណាងរាស្ត្រជួយ និងទៅមុខភូមិគ្រឹះ ហ៊ុន សែន ដើម្បីជួយអន្តរាគមន៍ក្នុងរឿងដីធ្លីត្រូវគេរំលោភបំពានស្ទើររាល់ថ្ងៃ ។

ជាមួយគ្នានេះដែរ លោក យ៉ាស ហ្គាយ អតីតតំណាងអគ្គលេខាធិការអង្គការសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ដែលរិះគន់មិនសំចៃមាត់ ចំពោះ ហ៊ុន សែន និងត្រូវបាន ហ៊ុន សែន បដិសេធមិនឱ្យចូលជួប និងមិនឱ្យសហការជាមួយ ហើយជំរុញឱ្យអង្គការសហប្រជាជាតិដក យ៉ាស ហ្គាយ ចេញពីតំណាងនៅប្រទេសកម្ពុជាទៀតផង ។

ដោយមើលឃើញពីស្ថានភាពសិទ្ធិមនុស្សកាន់តែអាក្រក់ទៅលោក ធន សារាយ និងលោកស្រី ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្សនៅកម្ពុជាបានទៅបញ្ចុះបញ្ចូលឱ្យអង្គការសហប្រជាជាតិដាក់ការិល័យរបស់ខ្លួននៅកម្ពុជាបន្តទៀត ពីព្រោះអង្គការសិទ្ធិមនុស្សសង្ឃឹមតែការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សទេ ដែលអាចផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋខ្មែរបាន ។

ជាឧទាហរណ៍លោកស្រី ពុង ឈីវកេក ជានាយិកាអង្គការសិទ្ធិមនុស្សលីកាដូ បានបញ្ជាក់ថា ការរំលោភសិទ្ធិមនុស្សក្នុងការបណ្តេញប្រជាពលរដ្ឋពីលំនៅឋានកាន់តែច្រើន ចំណែកប្រជាពលរដ្ឋដែលរស់នៅលើទឹកដីប្លង់កម្មសិទ្ធិស្របច្បាប់បែរជាខុសទៅវិញ ។

លោកស្រី ពុង ឈីវកេក បន្តថា ករណីបណ្តេញប្រជាពលរដ្ឋនៅខេត្តកំពត នៅចំណុចដីក្រហមក្រុងភ្នំពេញវាជារឿងមួយគួរឱ្យខ្លោចផ្សាខ្លាំងណាស់ ផ្ទះសម្បែងរបស់ប្រជាពលរដ្ឋត្រូវគេរុះរើ និងបង្ខំឱ្យចាកចេញពីលំនៅឋានរបស់ខ្លួនគួរឱ្យសង្វេគ ។

គួរបញ្ជាក់ថា តាមរយៈកម្មវិធីរបស់អង្គការ USAID បានឃើញលុយដែលបាត់ក្នុង1ថ្ងៃនៅកម្ពុជាប្រមាណជាង1លានដុល្លារ ដែលធ្លាក់នៅក្នុងដៃមន្ត្រីកាន់អំណាច ហើយមន្ត្រីគណបក្សប្រជាជនកម្ពុជាមួយចំនួនបានយកលុយកាក់ទាំងនេះទៅកសាងផ្លូវថ្នល់ដាក់ឈ្មោះខ្លួនឯងទៀតផង ។

ចំពោះបញ្ហាទាំងអស់នេះ ប្រទេសអ្នកផ្តល់ជំនួយហាក់ដូចជាមិនសូវចាប់អារម្មណ៍ទេ ពីព្រោះប្រទេសខ្លះដែលផ្តល់លុយឱ្យគេចង់បានចំណេញផ្នែកនយោបាយ និងប្រទេសខ្លះទៀតគេមានភាគហ៊ុនរកស៊ីនៅកម្ពុជាច្រើនមិនសូវខ្វល់ខ្វាយឡើយ ។

ពេលនេះអ្នកតាមដានឃ្លាំមើលសភាពការណ៍នៅកម្ពុជា បានសាទរចំពោះការផ្តល់ជំនួយរបស់អាមេរិកចំពោះកម្ពុជា ដែលទាមទារលក្ខខណ្ឌផ្នែកប្រព័ន្ធច្បាប់ និងសិទ្ធិមនុស្សឱ្យប្រសើរឡើង ប៉ុន្តែគេមិនសង្ឃឹមថា ទទួលបានលទ្ធផលនោះទេ ៕



សកម្មភាពរបស់សមត្ថកិច្ចបង្រ្គាប់ប្រជាពលរដ្ឋឱ្យចេញពីលំនៅឋាន

ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)

Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market) **(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.

**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**

**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:**

- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ត្វាំង ឆារសាច់គោ
- មីកន្ត្វាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:**

- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់សេជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ

ទំព័រវិធី បំភ្លឺជីវិត

# គំនិត និងសតិបញ្ញានាំមកនូវក្តីសម្រេចជោគជ័យ

ដោយ : អ៊ុម លឿង

●●●ក្តីសម្រេចជោគជ័យរបស់មនុស្សម្នាក់ៗ ពុំមែនអាស្រ័យទៅលើកំណប់ព្រេង សំពៅបុណ្យពីបុព្វជាតិឡើយ គឺអាស្រ័យនៅការខំប្រឹងប្រែង ខ្នះខ្នែងធ្វើដោយដៃទាំងពីរផ្ទាល់របស់យើង និងបានអំពីការគិតដ៏ត្រឹមត្រូវមួយតែប៉ុណ្ណោះ ។ បើយើងអនុវត្តនូវរូបមន្តទាំង១១ចំណុចខាងក្រោមនេះបាន នោះជីវិតយើងនឹងមានបាននូវភាពជោគជ័យជាពុំខាន ។

១- មានជំនឿជឿជាក់លើខ្លួនឯង ។

២-មិនប្រកាន់ភ្ជាប់នូវគំនិតចាស់គម្រិលហួសហេតុពេក ព្រោះគំនិតចាស់គម្រិលវាជាការបិទបាំងនូវអ្វីៗ ដែលល្អៗ ហើយថ្មីៗ ។

៣- បែងចែកពេលវេលាឱ្យបានសមរម្យ ។ ត្រូវគិតថា តើក្នុងមួយថ្ងៃៗ ត្រូវធ្វើអ្វីខ្លះ ? ។

៤- ទទួលស្គាល់នូវការពិតថា ជីវិតរបស់យើងមានចុះ, មានឡើង, មានបរាជ័យ, មានជ័យជំនះ, មានវិជ្ជមាន, មានអវិជ្ជមាន ហើយត្រូវទទួលស្គាល់នូវភាពបរាជ័យដែលធ្លាប់កើតមានពីពេលមុនៗ ។

៥- មានភាពទន់ភ្លន់ តែហ៊ឹងម៉ាត់ ហើយអាចផ្លាស់ប្តូរគំរោងផែនការណ៍ផ្សេងៗ ឱ្យបានសមស្របទៅនឹងស្ថានការណ៍បច្ចុប្បន្ន ។

៦- មិនបញ្ឈប់ការសិក្សាស្វែងរកនូវអ្វីៗ ដែលបានកើតឡើងជុំវិញខ្លួនយើង ព្រោះក្នុងលោកនេះមានវត្ថុផ្សេងៗ សម្រាប់ឱ្យយើងសិក្សាស្វែងយល់ ដោយពុំមានថ្ងៃបញ្ចប់ឡើយ ។

៧- មិនប្រមាថម៉ាកងាយលើសមត្ថភាពខ្លួនឯង និងត្រូវកំណត់គោលដៅឱ្យបានពិតប្រាកដក្នុងការសម្រេចធ្វើកិច្ចការអ្វីមួយ ហើយត្រូវប្តេជ្ញាធ្វើតាមគោលដៅនោះឱ្យបានជាដាច់ខាត ។

៨- ព្យាយាមយកជ័យជំនះលើបំណងប្រាថ្នារបស់ខ្លួន ដោយការស្វះស្វែងស្រាវជ្រាវ ស៊ើបរកចំណុចពិសេសរបស់ខ្លួន ហើយនាំយកនូវចំណុចពិសេសនោះមកប្រើប្រាស់ ដើម្បីបង្កើតឱ្យបានជាគុណប្រយោជន៍ ។

៩- ក្រលែកមើលអនាគតខាងមុខឱ្យបានវែងឆ្ងាយថែមទៀត និងព្យាយាមឱ្យតម្លៃចំពោះវត្ថុផ្សេងៗ ព្រមទាំងខ្លួនឯងផ្ទាល់ ។

១០- ឱ្យតម្លៃលើសមិទ្ធផលនានា ដែលកើតអំពីស្នាដៃយើងផ្ទាល់ ថាជាសមិទ្ធផលដ៏ធំអស្ចារ្យមួយ និងមានសារៈសំខាន់បំផុត ហើយថែមទាំងពង្រីង និងអភិវឌ្ឍន៍កិច្ចការទាំងនោះឱ្យកាន់តែមានភាពល្អប្រសើរ ។

១១- កុំយករឿងរ៉ាវតូចកុំប៊ិកកុំប៉ុកមកដាក់ក្នុងខ្លួន និងព្យាយាមមិនគិតនូវភាពបរាជ័យ, ភាពសោកសៅ និងភាពអពមង្គលផ្សេងៗ ក៏ប៉ុន្តែត្រូវផ្លាស់ប្តូរគំនិតដោយការត្រិះរិះ កែខៃរកវិធីសាស្ត្រក្នុងការដោះស្រាយរាល់បញ្ហាផ្សេងៗ ដែលអាចកើតឡើងជាយថាហេតុ ។

" មនុស្សយើងម្នាក់ៗ បើគិតថាល្អ នោះវានឹងល្អ , បើគិតថាឈានដើរទៅមុខ នោះនឹងបានដើរ ហើយបើគិតថា នឹងបានទទួលជោគជ័យ នោះថ្ងៃណាមួយពិតជាបានជោគជ័យជាក់ជាពុំខានឡើយ "

អ៊ុម លឿង

## ការសែតខ្មែរប៉ុស្តិ៍ នៅ " រ៉ូដអាឡែន "

❖❖❖លោកអ្នកអាន "ខ្មែរប៉ុស្តិ៍" នៅរដ្ឋអាឡិន អាចអញ្ជើញរកកាសែតរបស់អស់លោកអ្នកបាន នៅ ប្រូវិជិន តាមហាងពាណិជ្ជកម្មដូចតទៅ :

1- ASIAN STAR MARKET
618 ELMWOOD AVENUE
PROVIDENCE RI 02907

2- VIDEO CHHAY SAVANN
384 ELMWOOD AVENUE
PROVIDENCE, RI 02907
Phone :(401)588 9306

3- FRIENDSHIP MARKET
187 MESER STREET
PROVIDENCE, RI 02907
Phone : (401) 274 3744

4- KHMER WORLD VIDEO (KW)
310 RESERVOIR AVENUE
PROVIDENCE, RI 02907
Phone : 401- 467 5900

តម្លៃផលិតកាសែត នឹងធ្វើបានកើនឡើងយ៉ាងខ្ពស់ ហេតុនេះ សូមលោកអ្នកអានមេត្តាអធ្យាស្រ័យចំពោះការដាក់តម្លៃ ៥០សេន ក្នុងការជាវកាសែតមួយច្បាប់ ចាប់ពីពេលនេះទៅ ។ ទីចាត់ការខ្មែរប៉ុស្តិ៍ ៕


ការិយាល័យមេធាវី លិនហ្សេ ដ័រេង
LAW OFFICE OF LINDSAY DOERING
ទទួលការពារផលប្រយោជន៍លោកអ្នកករណីនានាតាមផ្លូវច្បាប់ដូចជា :
▸ ករណីបើករបរពាណិជ្ជកម្ម នឹងផ្ទេរប្រាក់ក្នុងមុខជំនួញ
▸ ករណីទិញលក់អចលនវត្ថុ ដូចជា: ផ្ទះសម្បែង ដីធ្លីជាដើម ។
▸ ករណីគ្រោះថ្នាក់រថយន្ត ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ
▸ ករណីអន្តោប្រវេសន៍
▸ ឬករណីឧក្រិដ្ឋកម្ម ។ល។

ធ្លាប់មានបទពិសោធន៍ខ្ពស់ ផ្តល់សេវាជូនតាមវិជ្ជាជីវៈ ហើយតម្លៃក៏សមរម្យទៀតផង យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។
General practice law office handling matters in :
Corporations and business Transations
Read Estate
Car Accidents
Work Place Injury
Immigration
Criminal Defense
Experienced, professional service and reasonable rate. Interpreter available.
Office: (215) 667-8118 2301 Delancey place, Philadelphia PA 19103
Cell : (215) 840-1364 Email : lindsaydoering@yahoo.com

ឱសថស្ថាន ផ្លូវលេខ 8
វេជ្ជបណ្ឌិត អាឡិច លឿង
8th Street Pharmacy
Alex. N. Luong, RPh.
OPEN HOURS:
Mon. – Fri.: 9:00AM – 7:00PM
Sat.: 9:00AM – 5:00PM
Sun.: 9:00AM – 3:00PM
បើចង់បានសេវាថ្នាំពេទ្យឆាប់ សូមអញ្ជើញមករកអ្នកភូមិរបស់អ្នក គឺឱសថស្ថាន ផ្លូវលេខ ៨ (ជ្រុងផ្លូវលេខ៨ និង CHRISTIANហ្វីឡា-ខាងត្បូង)

☛យើងទទួលប័ណ្ណមេឌីបែរ នឹងមេឌីខេត
▸We Do accept Medicare & Medicaid
▸ We Do Offer Alternative Natural Medicines Including:
☛យើងមានផ្តល់ជូននូវឱសថធម្មជាតិ មានដូចជា :
▶ Prostate -7 – ជួយដល់សុខភាព "ប្រស្តេដ" ដល់បុរស
▶ Pure Fresh Royal Jelly – ជួយលើកដំកើងនូវរសជាតិនៃជីវិត
▶ Fe-mon-9 – ជួយដល់ស្ត្រីនៅពេលមានអ័រម៉ូន
▶ Super Cross – ជួយបន្ថយការតាំងបេះដូង,ការលើសឈាម ឬកូឡេស្តេរ៉ុលច្រើន
▶ Gold Medal Swiss Placenta "សុកពពែស្វីស" មេដាយមាស សំរាប់កែសម្ផស្ស
819 S. 8th St.
Philadelphia, Pa 19147
Phone: 215-592-8888
Fax: 215-592-9888

ទំព័រ មនោសញ្ចេតនា

# ក្តីស្នេហ៍គ្មានទីបញ្ចប់...



**(តពីលេខមុន)**

●●●ថ្ងៃខែចេះតែកន្លងផុតទៅ សង្គ្រាមបានរីករាលដាលឆាបឆេះស្ទើរពេញនគរខ្មែរទៅហើយ ។ លោកសេនាប្រមុខ លន់ នល់ ស្រែកអំពាវនាវឱ្យយុវជនចូលបំរើកងទ័ពសាធារណរដ្ឋ ដើម្បីតតាំងវាយប្រឆាំងបណ្តេញទ័ពចោរទមិឡកុម្មុយនិស្តយួនខាងជើងឈ្លានពាន ។ ឯសម្តេចឪ គង់នៅប៉េកាំង ក៏ទ្រង់ស្រែកហៅកូនចៅឱ្យចូលព្រៃម៉ាគីយ៍ វាយរំដោះជាតិ ដណ្តើមយករាជ្យបល្ល័ង្គមកថ្វាយព្រះអង្គវិញ ។ សម្ព័ន្ធមិត្តរបស់ខ្មែរសាធារណរដ្ឋ គឺកងទ័ពវៀតណាមខាងត្បូង ក៏បានលើករេហ៍ចូលមករុករានទន្ទ្រានដេញកំចាត់ទ័ពយួនខាងជើង ដើម្បីពង្រឹងសាធារណរដ្ឋខ្មែរនៃលោកសេនាប្រមុខ លន់ នល់ ដ៏ក្មេងខ្ចី ក៏ដូចជាមានឱកាសដេញតាមសត្រូវរបស់ខ្លួនចូលមកក្នុងទឹកដីខ្មែរយ៉ាងស្របច្បាប់ផងដែរ ។ ជាយូរហើយ គេពុំមានឱកាសនោះសោះ ព្រោះព្រំសីមាដ៏ពិសិទ្ធរបស់យើងត្រូវបានរក្សាថៃ ដោយគត់មត់គួរសមល្មទោះបីពីមុនមកពួកវៀតកុង បានខំចូលមកពួនសម្ងំក្នុងដែនព្រំសីមាខ្មែរ បានដោយការធ្មេចភ្នែកពីអាជ្ញាធរនៃប្រទេសនេះ ។

ដែនដីខ្មែរបានក្លាយជាសមរភូមិយ៉ាងស្វ័យប្រវត្តិជាសារវន្តទៅហើយ សម្រាប់យួនទាំងពីរជាបដិបក្សនឹងគ្នានេះ ។ ខ្មែរទាំងសងខាងកំពុងដើរជាន់ដានចាស់នៃប្រវត្តិសាស្ត្រ ដែលដូនតាបានចារទុកមកហើយ តែខ្មែរពុំបានចងចាំទុកឱ្យមហាវិនាសកម្មគ្របដណ្តប់មកលើដែនដីរបស់ដូនតាម្តងហើយម្តងទៀតគួរឱ្យអនិច្ចារ ។

បើខ្មែរម្ខាងបានឈ្នះហើយ តើខ្មោះខ្មៀងលើស្មាខ្មែរពេលណានឹងត្រូវបានដោះយកចេញទៅ ? ។ នេះជាស្បែអន្តការ ដែលធ្លាប់បានគ្របដណ្តប់មកលើប្រវត្តិសាស្ត្រពូជពង្សអង្គរម្តងហើយម្តងទៀតយ៉ាងអាមាស់បំផុត ។ ក្នុងពេលដែលកងកម្លាំងពួកយួនខាងជើងកុម្មុយនិស្តនិងយួនវៀតកុង បានរីកធំធាត់ពីមួយថ្ងៃទៅមួយថ្ងៃយ៉ាងគំហុត រេហ៍ពលខាងសេនាប្រមុខ លន់ នល់ ហាក់ដូចជារួញស្វិតទៅជាលំដាប់ ព្រោះពេលលោកចាប់ផ្តើមកសាងរបបសាធារណរដ្ឋខ្មែរ ទ័ពមួយនគរខ្មែរមានតែបីម៉ឺននាក់ ដែលនៅសេសសល់ពីរបបរាជានិយម ហើយបានក្លាយខ្លួនមកជាទ័ពសាធារណរដ្ឋវិញ គួរឱ្យកំសត់ពេកកូវ ។ តើយកទៅច្បាំងជាមួយអ្នកណា ? ទាហានត្រូវជ្រើសរើសយ៉ាងប្រញិបប្រញាប់យកទៅច្បាំងដោយគ្មានការហ្វឹកហាត់ ។ នាយទាហានបានបណ្តុះបណ្តាលក្នុងប្រទេសផង និងនៅតាមមជ្ឈមណ្ឌលមួយចំនួននៅប្រទេសយួនខាងត្បូងផង ដើម្បីបំពេញនូវការខ្វះខាតកូនទាហាន និងនាយទាហានក្នុងល្បឿនមួយយ៉ាងយឺតមិនគ្រប់គ្រាន់តតាំងច្បាំងនឹងទ័ពឈ្លានពានបរទេសឡើយ ។ ក្នុងចំណោមនិស្សិតនាយទាហានចេញពីមជ្ឈមណ្ឌល ដាឡាត (វៀតណាមខាងត្បូង) ត្រឡប់មកដល់ស្រុកកំណើតវិញ ដើម្បីបំរើជាតិមុនគេបង្អស់នោះ មានរូបខ្ញុំមួយដែរ គឺកម្លោះវីរៈ ។ យើងទាំងអស់គ្នាមានចំនួនជាង១០០រូប បានចុះពីយន្តហោះនៅព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង ក្នុងឯកសណ្ឋាននាយទាហានយ៉ាងសង្ហា ស្មាទាំងពីរលំអដោយឋានន្តរសក្តិអនុសេនីយ៍ត្រីទឹកមាសភ្លឺអញ្ចាច ។ នេះបង្ហាញឱ្យដឹងថា ថេរវេលាជាងមួយឆ្នាំនៅក្នុង " ឡថែប " ហាត់ពត់លត់ដំ ដាឡាត យើងទាំងអស់គ្នាបានក្លាយជាកូនប្រុសក្លាហានស្ម័គ្រចិត្តពលីគ្រប់បែបយ៉ាងរហូតដល់ជីវិតរបស់ខ្លួន ព្រោះបុព្វហេតុជាតិ ។ បើពិតជារឿងទាំងអស់អនុវត្តន៍បានដូចវិន័យដែលយើងបានហាត់រៀនហ្វឹកហ្វឺននោះមែន នាយទាហានទាំងនេះអាចជាគំរូដឹកនាំដ៏ថ្លៃថ្នូរសម្រាប់យុវជនជំនាន់ក្រោយកងទ័ពពេលនេះនឹងក្លាយជាកូនដ៏ល្អរបស់ប្រជាជនច្បាំងនៅទីណាប្រាកដជាឈ្នះនៅទីនោះ ។ ពេលចុះពីយន្តហោះចេញមកដល់របៀងរង់ចាំ នៃញាតិមិត្តទាំងឡាយនោះមិត្តភ័ក្តិរបស់ខ្ញុំទាំងអស់គ្នាសុទ្ធតែមានសាច់ញាតិគេមកទទួលយកទៅគេហដ្ឋានរបស់គេរៀង១ខ្លួន ។ មិត្តខ្លះចង់ជូនខ្ញុំដែរ តែខ្ញុំបានអរគុណគេជាការគួរសមថា ខ្ញុំមានអ្នកមកទទួលដែរ តែគេមកយឺតបន្តិច ។ ការពិតខ្ញុំមានអ្នកណាជាសាច់ញាតិដែលមានរថយន្តមកទទួលនោះ ?



(តនៅទំព័រទី១៦)


# Washington Wellness Care






●បើលោកអ្នកមានគ្រោះថ្នាក់រថយន្ត,មានរបួសនៅកន្លែងធ្វើការ ឬក៏រអិល ហើយដួលរហូតដល់មានរបួសតែពុំដឹងនរណាជាអ្នកទទួលខុសត្រូវ ?

●**យើងអាចជួយលោកអ្នកបាន**

●មជ្ឈមណ្ឌល "វ៉ាស៊ីនតុនវែលណេសឃែ" មានបទពិសោធន៍ក្នុងរឿងរបួសក្នុងគ្រោះថ្នាក់រថយន្ត មានរបួសនៅកន្លែងធ្វើការនឹងរអិលដួលបណ្តាលឱ្យរបួស

●យើងណែនាំទៅមេធាវីដែលអាចការពារសិទ្ធិលោកអ្នកបាននៅពេលមានគ្រោះថ្នាក់

●អាចផ្តល់ផែនការណ៍ជួយចេញសោហ៊ុយចំពោះបុគ្គលដែលគ្មានប័ណ្ណធានារ៉ាប់រង

●សូមទូរស័ព្ទមក "វ៉ាស៊ិនតុនវែលខែល" ភ្លាម ដើម្បីឱ្យដឹងថា តើយើងអាចជួយលោកអ្នកដោយវិធីណា

**វីតី និយាយភាសាខ្មែរ លេខទូរស័ព្ទ : 215-380-1350**

- If you got into a car accident, fell injury at work, or slip & fall injured but not sure who you can turn to?
- **WE CAN HELP.**
- **The Washington Wellness Care Center is specialized in treating auto accident injuries, work related injuries, and slip andfall injuries.**
- **We also can refer you attorneys who can provide what your**
- **rights are when you got into the accident.**
- **Low payment plan available for individuals without insurance.**

500 Washington Ave., 1st Fl. Philadelphia, Pa 19147 Phone: 215-551-6838

# តើនយោបាយជាអ្វី ?

ដោយ : ម៉ម យិន

នយោបាយមិនមែនមុខរបរ
នយោបាយគាំទ្រកិច្ចការជាតិ
នយោបាយមិនមែនភូតភរទៀត
នយោបាយកុំឃ្លាតពាក្យសច្ចៈ ។
នយោបាយមិនមែនចង់សប្បាយ
នយោបាយចំណាយហ៊ានបង់លះ
នយោបាយមិនមែនចិត្តមានះ
នយោបាយប្រែផ្លាស់ដោះបញ្ហា ។
នយោបាយមិនមែនចងគំនុំ
នយោបាយត្រូវខំជួយប្រជា
នយោបាយមិនមែនចិត្តពាលា
នយោបាយជួយស្ដាការខូចខាត ។
នយោបាយមិនមែនគិតប្រយោជន៍
នយោបាយត្រូវស្រោចស្រង់ដល់ជាតិ
នយោបាយមិនមែនគិតតែឆ្មៀត
នយោបាយមិនឃ្លាតចិត្តត្រង់ស្មោះ ។
នយោបាយមិនមែនចិត្តលោភលន់
នយោបាយគិតគន់ជួយសង្គ្រោះ
នយោបាយមិនមែនរករឿងឈ្លោះ
នយោបាយស្រួលស្រុះឱ្យជាតិសុខ ។
នយោបាយមិនមែនចិត្តកំសាក
នយោបាយហ៊ានចាកហ៊ានចេញមុខ
នយោបាយមិនមែនដើរចាក់រុក
នយោបាយត្រូវផ្ទុកក្ដីក្លាហាន ។
នយោបាយមិនមែនអាងអំណាច
នយោបាយត្រូវខ្លាចច្បាប់ធរមាន
នយោបាយមិនមែនធ្វើបំពាន
នយោបាយត្រូវហ៊ានបង់កិត្តិយស ។
នយោបាយមិនមែនចិត្តឃោឃៅ
នយោបាយនាំផ្លូវជួយរំដោះ
នយោបាយមិនមែនអសប្បុរស
នយោបាយត្រូវស្មោះមិនឱ្យឃ្លាត ។
នយោបាយមិនមែនអួតក្អេងក្អាង
នយោបាយខំសាងគិតរឿងជាតិ
នយោបាយមិនមែនចិត្តប្រមាទ
នយោបាយឆ្លៀវឆ្លាតភាពឧត្ដម ។
នយោបាយមិនមែនបោកបញ្ឆោត
នយោបាយត្រូវយករាស្ត្រជាធំ
នយោបាយមិនមែនក្លែងបន្លំ
នយោបាយត្រូវខំសាងសុចរិត ។
នយោបាយមិនមែនលក់ខួរក្បាល
នយោបាយត្រកាលត្រូវតាំងចិត្ត
នយោបាយមិនមែនលួចប្រព្រឹត្ត
នយោបាយនាំជាតិមិនសាបសូន្យ ។
នយោបាយមិនមែនគិតតែឈ្លក់
នយោបាយឈប់វក់ឆប់ប្រើស្មៀត
នយោបាយមិនមែនចងអាឃាដ
នយោបាយដែលពិតស្ថិតក្នុងជាតិ ។
នយោបាយធ្វើតាមប្រាជ្ញបណ្ឌិត
នយោបាយនេះពិតគឺជាក្បួន
នយោបាយបាននាំជាតិនាំបងប្អូន
នយោបាយបានជូនជាតិសុខអើយ ៕




# ខ្មែរជួសជុលរថយន្ត

## KHMER AUTO REPAIR

CAR INSPECTION, DIAGNOSTIC & REPAIR

ត្រួតពិនិត្យរថយន្តតាមកុំព្យូទ័រ
- កែការកកើតម្លេងមួចមាតអ៊ឹមផូសប៉ុង
- ពើតធ្វើប្រាំង ឬ ប្រេក
- ត្រួតពិនិត្យធ្វើកាតុំខឱ្យដើរស្រួលឡើងវិញ
- បញ្ចេះម្យាររាលេ់យេអេកប៉័រ
- ប្តូរតេម្តមិកលើត្រាសម៉ំរ
- សេវាគ្រប់បើស្មុង
- ប៉េលតព្រហ្មទ្រនាប់និងកញ្ចក់

Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace.

5302 Rising Sun Avenue. Philadelphia, Pa 19120
215-939-5436

# New World Travel II

## ញូវើលត្រាវែលធូ

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុង ប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថៃ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបាន ទិញសំបុត្រជិះនាវាសមុទ្រ-សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

# ART OF WELLNESS CENTER



Art of Wellness
"Integrating Holistic Healthcare for the Mind, Body, and Spirit."
(215)305-2238
www.artofwellnesscenter.com



ទទួលព្យាបាលបានគ្រប់វ័យ

| របៀបព្យាបាល | TREATMENT TYPE |
|---|---|
| ប្រើម្ជុលឥតថ្នាំ | Acupuncture |
| ចាប់សរសៃ | Acupressure |
| ចិត្តវិទ្យា | Psychotherapy |
| យោគ/ ភាវនា | Yoga / Meditation |

វេជ្ជបណ្ឌិតនិងអ្នកជំនាញការមានបទពិសោធន៍ច្រើនឆ្នាំ នៅប្រទេសចិន និងនៅសហរដ្ឋអាមេរិក ៕

សូមអញ្ជើញទូរស័ព្ទ ឬមកមន្ទីរពេទ្យសុខភាពយើងខ្ញុំ ដើម្បីពិគ្រោះវិធីព្យាបាល

មន្ទីរសុខភាព "Art of Wellness" ទទួលព្យាបាលបញ្ហាផ្លូវចិត្តនឹងកាយធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នក របៀបបច្ចេកទេស និងបច្ចេកវិទ្យាបច្ចុប្បន្នប្រទេស ។

ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម:

| | | | |
|---|---|---|---|
| ធ្លាក់ទឹកចិត្ត | DEPRESSION | ឈឺខ្លួនប្រាណគ្រប់កន្លែង | PAIN MANAGEMENT |
| ការថប់អារម្មណ៍ | ANXIETY | មានវិបត្តិក្នុងគ្រួសារ | FAMILY ISSUES |
| ភាពតានតឹង | STRESS | ការញៀន និងអ្វីមួយ | ADDICTION ISSUES |
| មានកំហឹងច្រើន | ANGER MANAGEMENT | សុខភាពស្ត្រី | WOMEN'S HEALTH |

ART OF WELLNESS CENTER
647 BAINBRIDGE SREET
PHILADELPHIA, PA 19147
215-305-2238
ភាសាខ្មែរទាក់ទង ប៊ុន ក៏ត : 267-242-8526

(តមកពីទំព័រទី០២)

## សកម្មភាពនៅហ្វីឡាដែល...

ដោយមានឯកសណ្ឋាន និងឋានន្តរស័ក្តិកងទ័ពជាតិ ក្នុងក្របខណ្ឌ Join Volunteer Service Command កាលពីថ្ងៃទី១ មីនា ឆ្នាំ២០០៩ នៅវត្តបាលិល័យ ហ្វីឡាដែលហ្វីយ៉ាខាងត្បូង បានឱ្យដឹងថា :



អត្តសញ្ញាណប័ណ្ណស្របច្បាប់ បានចាប់បញ្ចេញឱ្យប្រើហើយ រួមគ្នានឹងការបើកឱ្យប្រើឯកសណ្ឋាន និងឋានន្តរស័ក្តជាកងឯកភាពផង ។

គេសង្កេតឃើញថ្នាក់ដឹកនាំ មានប្រធានគឺ លោក ថាច់ ខេមរិន្ទ និងអគ្គលេខាលោក សិរិត ប៉ែន ។

### V. កម្មវិធី " PEAK " នៅសហគមន៍ខ្មែរ "សាវវែល "

នៅហ្វីឡាដែលហ្វីយ៉ា ខាងត្បូងឈៀងខាងលិច ហៅថា " សាវវែល " មានសហគមន៍ខ្មែរប្រមាណ៥០០គ្រួសាររស់នៅទីនោះយ៉ាងស្ងៀមស្ងាត់ ។ ពីដើមជាតំបន់ដែលមានខ្មែរប្រមាណ ៥០០០នាក់រស់នៅ មានរបរពាណិជ្ជកម្ម និងការងារសម្បូរធ្វើគ្រាន់បើដែរ តែ៥ឆ្នាំចុងក្រោយនេះ ប្រជាជនបានចេញទៅរស់នៅតំបន់ផ្សេង មុខរបរក៏ថយចុះអស់ ។ គ្មានការគ្រប់គ្រងណែនាំអ្នកដែលនៅសល់ កំពុងរស់នៅក្នុងតំបន់នៃហ្វីឡាដែលហ្វីយ៉ា ពោរពេញដោយភាពក្រីក្រ និងអនាថា ដែលគ្រួសារនីមួយៗ មានការព្រួយបារម្ភ និងភ័យខ្លាចចំពោះអនាគតប្រកបដោយគ្រោះថ្នាក់របស់ខ្លួន ។

ជាមួយចាស់ទុំក្នុង " សាវវែល " ប្រមាណ ១០នាក់ នៅផ្លូវ ៦៧ និង " វូតឡិន " (wood land) នាថ្ងៃទី៥ មីនានេះ លោក ព្រិល- លោក ឈន- លោក ប៉ុក ... ។ល។ បានសម្តែងការចង់ឃើញកម្មវិធីពង្រឹងថាមពលគ្រួសារខ្មែរឱ្យមាំទាំ ក្នុងការជួយអប់រំកូនចៅ និងអប់រំគ្រួសារឡើងវិញ ។ កម្មវិធីណែនាំគ្រួសារខ្មែរមួយឈ្មោះ កម្មវិធី " ភីក " (PEAK) របស់សមាគម MHASP និងកាសែតខ្មែរប៉ុស្តិ៍ នឹងចូលរួមធ្វើសកម្មភាព "បង្កើនថាមពលគ្រួសារខ្មែរ" នៅតំបន់ "សាវវែល" នោះនៅពេលឆាប់ៗខាងមុខនេះ ។ សមាជិកចាស់នៅកម្មវិធី "ភីក" ដូចជា លោក សិរិត ប៉ែន. លោក ម៉ម យិន ក៏បានចូលរួមជួយផ្សព្វផ្សាយពន្យល់ពីគុណប្រយោជន៍កម្មវិធីសម្រាប់ពង្រឹងគ្រួសារខ្មែរផងដែរ ។



### VI. កម្មវិធីរបាំប្រពៃណី នៅហ្វីឡាដែលហ្វីយ៉ា " PFP"

កម្មវិធីសិក្សាសិល្បះប្រពៃណីខ្មែរមួយ ត្រូវបានរៀបចំជូនយុវជនដែលមានអាយុឆាប់ពី ៨ ដល់១៨ឆ្នាំ នាឱកាសឈប់សម្រាប់ខាងមុខ ។ គ្រូបង្ហាត់ ភិម ថាវ៉ូ និង យិន ចំរើន នឹងធ្វើការបង្ហាត់បង្រៀនរបាំប្រពៃណី បង្រៀនប្រវត្តិសាស្ត្រ និងវប្បធម៌ នៅចន្លោះថ្ងៃទី៦ ដល់១០មេសា ឆ្នាំ២០០៩ ពីម៉ោង ៩:០០ ដល់ ម៉ោង ៤:០០ នៅវត្តព្រះពុទ្ធរង្សី ជ្រុងផ្លូវលេខ ៦ខាងត្បូង និងផ្លូវ រីតន័រ (Ritner St.)

PFP អំពាវនាវឱ្យយុវជន យុវនារីអញ្ជើញមកចុះឈ្មោះឱ្យបានឆាប់ ដោយទូរស័ព្ទទៅលេខ 215-726-1106 ឬក៏ចូលមើលនៅ វេបសាយ www.folkloreproject.org.

**The Khmer Post Directory**

**East Coast Publication**

Regional Editor : Pin Samkhon

Email : pinsamkhon@gmail.com

Writers : Mam Yin
Kim Phean
Im Loeurm
Chhan Young

**Advertising**

Marketing/Advertising Manager: Sabane Thach

Phone : 267-253-3947

Email : sabane.thach@gmail.com

**West Coast Publication**

RegionalEditor : Sovannara Meach

Writers : Kim Saroeurn
Ra Neat
Sophea Rith
Mey Sampos
Chan Kosal
Sovann Rith

Phone: (562) 313-2129

Email: sovannara04@yahoo.com






# ទំនាយមហាសង្ក្រាន្តឆ្នាំថ្មីបង្ហាញពីគ្រោះមិនសូវល្អ



●●●សៀវភៅមហាសង្ក្រាន្តឆ្នាំថ្មី សំរាប់ឆ្នាំឆ្លូវ ព.ស ១៥៥៣ គ.ស ២០០៩ បានចេញផ្សាយហើយ ដោយធ្វើ ការទស្សន៍ទាយតាមទំនាយប្រចាំឆ្នាំថា នរគនឹងមានគ្រោះអាក្រក់ច្រើនគួរឱ្យភ័យខ្លាច ។

មហាសង្ក្រាន្តឆ្នាំឆ្លូវ នឹងចូលមកដល់នៅថ្ងៃអង្គារ ៥រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែមេសា គ.ស ២០០៩ នៅវេលាម៉ោង១ និង៣៦នាទី រំលងអាធ្រាត្រ ។ ទេព្តាឆ្នាំថ្មីនេះ ព្រះនាមរាក្សសាទេវី ជាបុត្រទី៣ នៃកបិលមហាព្រហ្មគង់នៅមហាចតុម្មមហារាជិកាទ្រង់អម្ពរពណ៌ខ្មៅ លំអនៅលើព្រះកាណ៌ ដោយផ្កាឈូករតន៍អភរណៈ ទ្រង់ពាក់កែវមោរាភក្សាហារ ទ្រង់សោយលោហិត (ឈាម) ព្រហស្តស្តាំទ្រង់ត្រីសូល៍ព្រហស្តឆ្វេងទ្រង់ធ្នូ ទ្រង់គង់ផ្ទំបិទព្រះនេត្រលើខ្នងសត្វអស្សតរ (សេះ) ជាពាហនៈ ។

**- ពេលវេលាត្រូវទទួលទេព្តាឆ្នាំថ្មី :**

រៀបចំសំពត់ក្រាលក្រហម ហើយរៀបចំបាយសី៩ថ្នាក់មួយគូ បាយសី៧ថ្នាក់មួយគូ បាយសីប៉ាឆាមមួយគូ ស្លាធម៌មួយគូ ទឹកអប់មួយគូ ទៀន៥ ធូប៥ លាច៥ផ្កា ដាក់លើជើងពានមួយគូ ចេកនួន ចេកណាំវ៉ាមួយគូ ផ្លែឈើ១១មុខ រៀបដាក់ជើងពានជាគូៗ ដូងឡៅមួយគូ ។ ឆ្នាំនេះគួរមានផ្កាពណ៌ក្រហម និងសំណាកជ្រូក និងសេះ ដាក់ទទួលទេព្តាផង ។

**- ទំនាយទឹកភ្លៀងឆ្នាំនេះ :**

ទឹកភ្លៀងបង្អុរ៥០០មេ ចែកចេញជាចក្រវាឡ ២០០មេ ព្រៃហិមពាន្ត១៥០មេ មហាសមុទ្រ១០០មេ និងជម្ពូ ទ្វីបមនុស្សលោកយើងមានត្រឹមតែ៥០មេប៉ុណ្ណោះ ។ ដើមឆ្នាំកណ្តាលឆ្នាំ ចុងឆ្នាំ ភ្លៀងស្មើគ្នាល្អ ។ ខ្យល់ព្យុះមានច្រើន ទឹកទន្លេមេគង្គឆ្នាំនេះជំនន់ ដោយទឹកភ្លៀង និងទន្លេមានជាមធ្យម គឺមានកំរិតពី៨ទៅ១៦ម៉ែត្រ ។

ទិន្នផលធ្វើស្រូវស្រែចំការ ស្រូវសំណាប ចំការផលដំណាំរបស់កសិករបានតែពាក់កណ្តាល ខូចអស់ពាក់កណ្តាល ។ ប្រជានុរដ្ឋមានសេចក្តីសុខខ្លះ ទុក្ខខ្លះស្មើគ្នា។

បើយោងតាមទំនាយថ្ងៃសង្ក្រាន្ត បានទស្សន៍ថា ថ្ងៃ ចូលឆ្នាំដំបូង គឺត្រូវនឹងថ្ងៃអង្គារ ទំនាយទាយថា ឆ្នាំនេះ នឹងអន្តរាយកណ្តាលទីក្រុងកើតមានភ្លើងឆេះយ៉ាងសាហាវ កើតនូវចិត្តកាចច្រើនឡើងៗ មនុស្សប្រែប្រជាមានចិត្តអាក្រក់ជំងឺដង្កាត់មានច្រើនជាទីបំផុត ។ មនុស្សផងទាំងឡាយនឹងកើតទុក្ខ រោគភ័យស្លាប់ព្រោះជំងឺ ផែនដីនឹងស្ងួតហួតហែង ដើមឆ្នាំនឹងមានភ្លៀងបន្តិចបន្តួច ។ ប្រទេសនឹងកើតកលិយុគសង្គ្រាមច្បាំងគ្នាមនុស្សផងទាំងឡាយទទួលនូវក្តីលំបាកជាច្រើនអនេក ។

**- ទំនាយថ្ងៃវ័នបត គឺថ្ងៃកណ្តាលឆ្នាំ :**

**ថ្ងៃកណ្តាល :** ត្រូវនឹងថ្ងៃពុធ ទំនាយទាយថា ស្រូវ អង្ករ ផ្លែឈើឡើងថ្លៃ មនុស្សទាំងឡាយក្តៅក្រហាយចិត្តច្រើនជាទីបំផុត ស្ត្រីទាំងឡាយនឹងត្រូវនិរាសព្រាត់ប្រាសពីទីកន្លែងរស់នៅទៅនៅជ្រកកោនទីដទៃផ្សេងៗ គ្នា ។

**- ទំនាយថ្ងៃឡើងស័ក្តិ :**

ថ្ងៃចូលឆ្នាំចុងក្រោយ ត្រូវនឹងថ្ងៃព្រហស្បត្តិ៍ ទំនាយទាយថា សមណៈព្រាហ្មណាចារ្យនឹងប្រណិប័តន៍ចូលចិត្ត ដោយធម៌ ដែលប្រសើរវិសេសមានន័យថា មនុស្សទាំងឡាយទាមទារឱ្យប្រព្រឹត្តអំពើល្អយកធម៌អហិង្សាក្នុងខ្លួន ។

បើទោះបីមហាសង្ក្រាន្តឆ្នាំនេះ ត្រូវបានទស្សន៍ទាយថា មានហេតុភេទអាក្រក់សំរាប់ស្រុកទេសក៏ដោយនេះ គ្រាន់តែជាការទាយប្រចាំឆ្នាំតាមក្បួនហោរាស្ត្រពីទំនៀមទម្លាប់តែប៉ុណ្ណោះ ៕

(អត្ថបទដកស្រង់ពីកាសែតកម្ពុជាថ្មី)

Nationwide

Insurance & Financial Service

សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

យើងធ្វើជូនគ្រប់គ្នាដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រងសុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance

ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

អិលធី សាលាសំអាងសម្ផស្សអន្តរជាតិ

LT INTERNATIONAL BEAUTY SCHOOL, INC.



*Hands on Training...*
*For a Better Future*

និស្សិតនឹងរៀនវិជ្ជាដោយផ្ទាល់ដៃ ដើម្បីឱ្យបានអនាគតល្អ ប្រសើរជាពិសេស

-យើងអាចទទួលសិស្សដែលមាន វីសា I-20 បាន សំរាប់រៀនរយៈពេលមួយឆ្នាំ ឬក៏យូរជាងនេះ

-យើងទទួលការដាក់ពាក្យពីប្រទេសក្រៅ ដូចជា : មកពីប្រទេសកម្ពុជាសំរាប់ការសិក្សា ។

ក្នុងករណីនេះ យើងរកផ្ទះឱ្យនៅនឹងម្ហូបអាហារផ្តល់ជូន

ប្រយ័ត្ន : យើងនឹងអាចរកជំនួយហិរញ្ញវត្ថុជូន សំរាប់តែនិស្សិតណាដែលមានសិទ្ធិ (គ្រួសារមានប្រាក់ចំណូលតិចតួច ឬគ្មានសោះ)

យើងជាសាលាដែលមានការទទួលស្គាល់ពីស្ថាប័នរដ្ឋ ខាងផ្នែកសំអាងសម្ផស្សរាប់ទាំង ការធ្វើសក់ ក្រចក ឬស្បែក ។

និស្សិតអាចជ្រើសរើសការសិក្សាវិញ្ញាសាដាច់ម្តងមួយក៏បាន



យក Coupon នេះមកជាមួយនឹងបញ្ចុះថ្លៃជូន

$500

ផុតកំណត់នៅថ្ងៃ ០៥ កុម្ភៈ ២០០៩

Financial-Aid available, for those who qualified

Massage

៣០០ ម៉ោង

Office #1
830 N. Broad Street.
Philadelphia, Pa 19130
Tel : 215-922-4478
Fax : 215-763-2860

Office #2
2520-22 N. Broad Street.
Philadelphia, Pa 19132
Tel : 215-229-0390
Fax : 215-229-0391

www.ltinternationalbeautyschool.us Email: ltibs@verizon.net

(តមកនៅទំព័រទី០១)

## Stimulus ទប់ស្កាត់វិបត្តិ...

នៅផ្ទៃករដ្ឋបាលវិញ រដ្ឋអំណាចបានផ្តាច់ចោលឈប់ជួយដល់កម្មវិធីថែទាំ និងអប់រំក្នុងក្រុងមួយចំនួនរួចហើយ ហើយមួយចំនួនទៀតកំពុងរង់ចាំសេចក្តីសម្រេចរបស់ចៅហ្វាយក្រុងថា បុគ្គលិកកម្មវិធីណាខ្លះ ដែលនឹងត្រូវរង់ឥទ្ធិពលនៃការកាត់ថវិកានោះជាបន្តបន្ទាប់ទៀត ។

ក្នុងពេលដែលសេចក្តីព្រួយបារម្ភ កំពុងរីករាលដាលពេញសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា បានចុះហត្ថលេខាបញ្ចេញថវិការដ្ឋពីរដង ចំនួនប្រមាណ ១ពាន់ប៊ីលីយ៉ុង ដើម្បីមកជួយស្តារិបត្តិដ៏ធ្ងន់ធ្ងររបស់សហរដ្ឋអាមេរិកឱ្យខានតែបាន ។ ប្រាក់ដែលមានចំនួនដ៏ច្រើននេះ នៅពុំទាន់គ្រប់ចំនួនសម្រាប់តម្រូវការនៅឡើយមែន ក៏ប៉ុន្តែគេសង្ឃឹមថា នឹងផ្តល់ថាមពលឱ្យរោងចក្រធំៗបញ្ឈប់ការបណ្តេញបុគ្គលិក កម្មករ ទប់ស្កាត់កុំផ្ទះសម្បែងពលរដ្ឋត្រូវធនាគាររឹបអូសជាបន្តបន្ទាប់ទៀត ជួយសាលារៀន និងស្ថាប័នរដ្ឋឱ្យដំណើរការណ៍ប្រក្រតីបាន ដោយពុំចាំបាច់ កាត់បន្ថយបុគ្គលិក ឬសកម្មភាពជួយឱ្យឧស្សាហកម្ម សំណង់ ឬពាណិជ្ជកម្មងើបឡើងវិញបាន។ Stimulus នេះ ពុំមានបំណងត្រឹមតែធ្វើឱ្យសេដ្ឋកិច្ចស្ទុះងើបឡើងវិញតែប៉ុណ្ណោះទេ គេសម្លឹងឃើញមានបំណងកែទម្រង់ជាច្រើន ដូចជា បំណងប្តូរការប្រើប្រាស់ថាមពល បំណងបង្កើនគុណភាពសិក្សាធិការ បំណងបង្កើនគុណភាពព្យាបាលជម្ងឺ បំណងបញ្ចប់សង្គ្រាម ដោយមិនបន្តកិត្យានុភាពសហរដ្ឋអាមេរិកនោះទេ ។

វិបត្តិនៅសហរដ្ឋអាមេរិក បានបណ្តាលឱ្យក្លាយទៅជាវិបត្តិក្នុងសកលលោកទៅហើយ ដោយសារប្រទេសទាំងនោះ មានទំនាក់ទំនងសេដ្ឋកិច្ចយ៉ាងជិតស្និតជាមួយនឹងសហរដ្ឋអាមេរិក ។ បារាំង-ចិន-ជប៉ុន ... ។ល។ កំពង់តែជួបវិបត្តិដូចសហរដ្ឋអាមេរិកនេះដែរ តែប្រទេសទាំងនេះ ពុំមានខ្ទង់ចំណាយធំក្នុងសង្គ្រាមធំដូចសហរដ្ឋអាមេរិកទេ ដូច្នេះមានភាពងាយស្រួលនឹងទប់ទល់ជាង ។ ប្រទេសទាំងនេះ រកស៊ីជាមួយផ្សារអាមេរិកាំង បានរហូតដល់អ្នកទិញអាមេរិកាំង ខ្សត់លុយធ្វើឱ្យផលិតផលបរទេសយកមកលក់នៅសហរដ្ឋអាមេរិកមិនដាច់ ។ នៅកម្ពុជាគ្មានសេដ្ឋកិច្ចអ្វីជារបស់ផ្ទាល់ខ្លួនទេ គឺផលិតផលសម្រាប់លក់ឱ្យអឺរ៉ុប និងអាមេរិកទាំងអស់ ហើយម្ចាស់រោងចក្រជាបរទេស គេរកស៊ីមិនបាន គេគេចខ្លួនមិនសងប្រាក់បៀវត្សរ៍កម្មករ មិនបង់ពន្ធដារ រីឯធនាគារខ្មែរក្នុងពេលនេះ គេឃើញតែចលនាដកលុយចេញ ពុំមានដាក់ចូលធនាគារវិញទេ នេះជាបុព្វហេតុធ្វើការងារសេដ្ឋកិច្ច ពាណិជ្ជកម្ម និងហិរញ្ញវត្ថុនៅកម្ពុជា គាំងដំណើរស្ទេញ ។

អ្នកវិភាគសេដ្ឋកិច្ច និងពលរដ្ឋអាមេរិកាំង រាប់ទាំងខ្មែរអាមេរិកាំងផងដែរ ពុំបានមើលឃើញថា Stimulus មិនគ្រាន់តែទប់ស្កាត់គ្រួសារខ្លួន កុំឱ្យស្លាប់តែប៉ុណ្ណោះទេ គេសង្ឃឹមថា Stimulus នេះប្រាកដជាឱកាសដ៏ល្អមួយសម្រាប់ទិញ "ស្តុក Stock " ដែលតម្លៃហ៊ុនល្អៗកំពុងតែមានការចុះថោក ។ល។ សហរដ្ឋអាមេរិក នៅពេលដកទិញមកវិញអស់ពីបរទេសនឹងកាត់បន្ថយចំណាយធំជាងគេបង្អស់ ១២ ប៊ីលីយ៉ុង ក្នុង១ខែ នេះជាសេចក្តីសង្ឃឹមថា សហរដ្ឋអាមេរិក អាចនឹងធ្វើឱ្យថវិកាជាតិកើនមកវិញយ៉ាងជាក់ស្តែង ហេតុនេះហើយបានជាមតិសាធារណៈនិយាយថា វិបត្តិសហរដ្ឋអាមេរិក មិនអាចធូរស្រាលបាននៅមុនរយៈពេលពីរឆ្នាំខាងមុខនោះទេ ។

ប្រាក់ Stimulus មិនទាន់ចេញផុតពីធនាគារកណ្តាលផង រដ្ឋបាល អូបាម៉ា ផ្តើមនិយាយអំពីការរកលុយ ដើម្បីសងខ្ទង់ចំណាយ Stimulus ចំនួន ៣ពាន់ប៊ីលីយ៉ុង នៅបីឆ្នាំខាងមុខរួចទៅហើយ ។ ដោយយោងទៅតាមការប្រុងប្រយ័ត្នដ៏តឹងរឹងនេះ នឹងធ្វើឱ្យកើតការទុកចិត្តបន្ថែមដល់រដ្ឋបាលកាន់តែច្រើន ។ ការទុកចិត្តបណ្តាលឱ្យមានការចូលរួមកសាងជោគជ័យគ្រប់យ៉ាង សង្ឃឹមថានឹងបានជួបជាមិនខាន ៕

### ក្លឹបសារព័ត៌មាន : (PRESS CLUB)

ក្លឹបសារព័ត៌មាននឹងលើកបញ្ហា Stimulus ដ៏ស្មុគស្មាញពិបាកយល់នេះ មកពិចារណាថា តើសហគមន៍ខ្មែរ នឹងទាញយកផលចំណេញដោយរបៀបណា ? ត្រូវធ្វើដូចម្តេច ? ពិគ្រោះជាមួយនរណា ?

សូមអញ្ជើញចូលរួមសកម្មភាព PRESS CLUB នៅថ្ងៃទី២៩ March ២០០៩ វេលាម៉ោង ១១:៣០ព្រឹក នៅភោជនីយដ្ឋាន New Golden Palace ជ្រុងផ្លូវ 8th WASHINGTON AVE. PHILADELPHIA. ទូរស័ព្ទ **267-253-3947**.

(តមកពីទំព័រទី០១)

## រាត្រីសមោសរ...

នៅក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី រាត្រីសមោសរនឹងត្រូវបានរៀបចំឡើង នៅសាលមហោស្រពជាតិចតុមុខចំនួនពីរដង គឺនៅរាត្រីថ្ងៃ ព្រហស្បតិ៍ ទី ២៨ និងរាត្រីថ្ងៃសុក្រ ទី ២៩ ខែឧសភា ឆ្នាំ២០០៩ ខាងមុខនេះ ។ នៅក្នុងរាត្រីសមោសរទាំងពីរនេះ មានចម្រៀង តន្ត្រី និងរបាំបុរាណ ដែលនឹងត្រូវបានប្រគុំ និងសំដែងជូនទស្សនាដោយសិល្បករ និងតន្ត្រីករ ដែលមានឈ្មោះល្បីនៅលើឆាកអន្តរជាតិ ។

រាត្រីសមោសរទីមួយនឹងត្រូវបានរៀបចំឡើង ដើម្បីថ្វាយព្រះករុណាព្រះមហាក្សត្រដែលមានការចូលរួមពីមន្ត្រីរាជរដ្ឋាភិបាល ស្ថានទូត ស្ថាប័ន និងសមាគមជាតិ និងអន្តរជាតិនានា ។

រាត្រីសមោសរទីពីរ គឺសម្រាប់អ្នកឧបត្ថម្ភកម្មវិធីនេះ សម្រាប់ភ្ញៀវរដ្ឋជាអ្នកឧបត្ថម្ភកម្មវិធី និងសម្រាប់សាធារណជនទូទៅដែលទទួលបានលិខិតអញ្ជើញ ។

អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ តស្ស ទីប្រឹក្សាអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រប្រធានគម្រោង ។

ទូរស័ព្ទ : ០១២ ៥៥ ៤០ ២០
អ៊ីម៉ែល : tesiso@hotmail.fr


# Randolph C. Smith




## Attorney at Law
## 267-324-6503

**Office # 1**
**1819 JFK Blvd.**
**Philadelphia, Pa 19103**

**Office # 2**
**1115 S. 11th St.**
**Philadelphia, Pa 19147**

ការិយាល័យច្បាប់យើងខ្ញុំ មានចំនាញខាងករណី គ្រោះថ្នាក់រថយន្ត
☞ ការរបួសនៅកន្លែងធ្វើការ ☞ បើកបរក្រោមឥទ្ធិពលស្រវឹង
☞ ករណីឧក្រិដ្ឋកម្ម និងអន្តោប្រវេសន៍ យើងនឹងយកចិត្តទុកដាក់ពីរថយន្តពីអ្វីទាំងអស់ដោយមិនឱ្យលោកអ្នកចំណាយប្រាក់ខ្លួនឯងឡើយ ។
បើចង់ដឹងអ្វីបន្ថែមសូមហៅរក **សុធា : (267) 324-6503**

We are specialty in Car Accident, Work Injury, DUI, Criminal Matter, and Imminration.

We will take care of your car and everything else without your pochet expense.
Please contact Sothia at 267-324-6503 for more information.

# The Noni Juice

ទឹកផ្លែមផ្លែ"ណូនី"ខ្មែរហៅផ្លែ"ញ"ត្រូវគេចងចាំថា ឪពុកម្តាយ ឬជូនតា ធ្លាប់យកផ្លែ "ញ" នេះទៅត្រាំស្រា ហើយពិសារជាថ្នាំព្យាបាលការឈឺចុកចាប់នានា បណ្តាលឱ្យមានកម្លាំង-ចុះកម្លាំងឈាម ។ល។ ឥឡូវនេះ អ្នកវិទ្យាសាស្ត្រខាងពេទ្យរកឃើញថា ផ្លែ"ញ" នេះ បើប្រើឱ្យសមគួរ... ឈាមបន្ថយការឈឺសន្លាក់ដៃជើងព្យាបាលជំងឺទឹកនោមផ្អែម-ធ្វើឱ្យមានកម្លាំង និងជួយរំលាយអាហារទៀតផង។
សូមទាក់ទងតាមឈ្មោះ និងទូរស័ព្ទខាងក្រោម ដើម្បីបានទឹកផ្លែម"ណូនី"




Philadelphia: David: 215-268-4821 or Jason: 215-805-3396
Rhode Island: Hui Le: 401-640-5158
Lowell: Samran: 508-216-6062
The Noni Jucie is made by traditional method, 100% pure, and no preservation. It can help decrease high blood pressure; reduce arthritis pain, diabetes, increase body energy level and digestion system.

# Legal Workshop សិក្ខាសាលាអំពីផ្លូវច្បាប់

**You and your family are invited to attend this FREE workshop on the following topics:**

- **Criminal Law**
- **Immigration**

**Date:** Saturday, March 21, 2009
**Time:** 10:00 AM - 12:00 PM
**Location:** Cambodian Association
5412 North 5th Street
Philadelphia, PA 19120

**Get your questions answered by a legal expert!**

យើងខ្ញុំសូមអញ្ជើញលោកអ្នក និងគ្រួសារមកចូលរួមក្នុងកម្មវិធី សិក្ខាសាលាអំពីផ្លូវច្បាប់ដូចខាងក្រោម :

- អ្វីទៅដែលជាទោសឧក្រិដ្ឋ
- អ្វីដែលទាក់ទងនឹងច្បាប់អន្តោប្រវេសន៍

កាលបរិច្ឆេទ : ថ្ងៃសៅរ៍ ទី ២១ ខែមិនា ឆ្នាំ២០០៩
ម៉ោង : 10:00 ព្រឹក - 12:00 ថ្ងៃត្រង់
ទីកន្លែង : សមាគមខ្មែរតំបន់ហ្វីឡាដែលហ្វា
5412 North 5th Street
Philadelphia, PA 19120

សំនួរទាំងអស់របស់លោកអ្នកនឹងត្រូវបានឆ្លើយដោយអ្នកជំនាញខាងផ្លូវច្បាប់ ។ យើងនឹងមានបំរើជូនអាហារសម្រន់ ។

**Cambodian Association of Greater Philadelphia**

**សមាគមខ្មែរតំបន់ហ្វីឡាដែលហ្វា**

**For more information, please contact:**

**សំរាប់ពត៌មានបន្ថែមសូមទាក់ទងមក :**

**Ms. Lang Chheng at lang@cagp.org**
**(215) 324-4070**



**HPC** Building Connections to Health

សមាគមខ្មែរតំបន់ហ្វីឡាដែលហ្វា
CAMBODIAN ASSOCIATION OF GREATER PHILADELPHIA, INC.

The Cambodian Association of Greater Philadelphia (CAGP) in collaboration with Health Promotion Council (HPC), a CCHCP authorized training agency in PA, is pleased to present…

## Community Healthcare Interpreter Training (CHIT)

- If you are proficient in English and another language;
- If you work as an interpreter, or interpret occasionally at work;
- If you are interested in the field of medical interpreting and want to make a good living using your language skills;

Then this training is for you!

This training will be provided by HPC, a CCHCP authorized training agency in Pennsylvania and the Delaware Valley since 1998, and a guest trainer from Seattle, Washington State.

This course follows the model **"Bridging The Gap"** established by the Cross Cultural Health Care Program (CCHCP) of Seattle, Washington under a licensed agreement. It covers the role of the interpreter, code of ethics, modes of interpreting, managing the flow of a session, sight translation, memory development, the US health care system, anatomy and medical procedures, cultural awareness, communication skills, professional development and more.

CHIT also provides participants with a 400-page interpreter manual, medical glossaries, culture-specific materials, and a guide to medications and a certificate of completion. Certification will be issued after successful completion of the entire training directly from CCHCP. Space is limited to 15 people, so register early!

**Dates:** April 23, 24, 25 and May 1, 2
**Time:** 8:30am – 4:30pm (light breakfast and snacks provided)
**Location:** 260 South Broad Street, 18th Floor, Philadelphia, PA 19102
**Total Fee:** $400.00 per person (Payable to CAGP, 5412 N. 5th St., Philadelphia, PA 19120)

Please complete the registration form below and fax it to Rorng Sorn at 215-324-2995. For more information, call 215-324-4070 or email: rorng@cagp.org

**Registration Form**

Name: ____________ M/F ______ Age ______
Agency: ____________
Address: ____________
Phone: ____________ Fax/Email: ____________
Which training do you prefer to attend? Feb: ____ April: ____ July: ____ Nov: ____
Which languages do you interpret well? ____________
How long have you been interpreting? ______ Years, Where: ____________

*HPC is a CCHCP authorized training agency in PA. The training is provided by the CCHCP authorized trainer.*

**Repro Center** 怡保印刷中心
*the printer you can trust*
*Since 1993*

1531-33 South 7th Street
Philadelphia • PA 19147
**T: 215.271.5041 /5042**
F.: 215.271.5043 • reprocenter@usa.net

- **Fast, Easy Print Ordering**
- **Premium Quality**
- **Low Price**
- **Excellent Customer Service**

BUSINESS CARDS *as low as* $15



## សេវាបោះពុម្ព

- តារាងម្ហូបភោជនីយដ្ឋាន
- លិខិតចំលងគ្មានកាបូន
- ខតអស័យដ្ឋាន
- ស្រោមសំបុត្រ
- ថតចំលងពណ៌ឌីជីថល
- សេវាបញ្ញើលិខិត
- កាតាឡុកសៀវភៅ
- ខិត្តប័ណ្ណបត់ជាសៀវភៅ
- ខិត្តប័ណ្ណលាត
- រូបផ្ទាំងស្អាតតូចៗ
- ផ្ទាំងរូបផ្ទាំងធំៗ
- ប្រតិទិន
- ធ្វើហ្វូលឌ័រសំរាប់ផ្សាយ
- បកប្រែភាសា
- គូសក្រាហ្វិក
- ធ្វើត្រាមាស
- អ៊ុតលើក្រប
- ធ្វើក្រប
- ប៉ាក់លើក្រណាត់ ឬសូត្រ





**Services Products**

| | | |
|---|---|---|
| Restaurant Menu | Catalogs / Booklets | Translation |
| Carbonless NCR Form | Brochures | Graphic Design |
| Business Cards | Flyers | Gold Foil Stamping |
| Envelopes | Postcards | Laminating |
| Letterhead | Posters | Labels |
| Digital Color Copy | Calendars | Clothing Embroidery / Silk Screen |
| Mailing Services | Presentation Folder | |



នាទី ប្រវត្តិសាស្ត្រ

# ទំព័រហ្វីឡាដែលហ្វីយ៉ា

## ពីរដ្ឋបាលក្រុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

ដោយ : ពិនសំខុន តពីលេខមុន

(តទៅលេខក្រោយ)

**ខែមីថុនា** : សាឡុតស (ឬ ប៉ុល ពត) កែវ មាស និងថ្នាក់ដឹកនាំកុម្មុយនិស្តខ្មែរ បានចេញដំណើរពី " ការិយាល័យ១០០ " សំដៅទៅទីក្រុងហាណូយ តាមផ្លូវលំហូជីមិញ ដំណើរថ្មើរជើង បានប្រើពេល៩ខែ ជួបជាមួយខ្មែរកុម្មុយ-និស្តនៅយៀកណាម តាំងពីឆ្នាំ ១៩៥៤ ដូចជា កែវ មុនី គេពិភាក្សាសម្ងាត់ជាមួយថ្នាក់ដឹកនាំយៀកណាម មានលោក ឡេ ឌ្វាន ។ បន្ទាប់មក សាឡុតស បន្តដំណើរពីហាណូយទៅប៉េកាំង សំណាក់នៅពីរខែ បានជួបនឹង ម៉ៅ សេទុង, លីវ យ៉ាវជី, ដេង សាវពីង បន្ទាប់មកក៏ចេញដំណើរទៅព្យុងយ៉ាង រដ្ឋធានី កូរ៉េខាងជើង យ៉ាងសម្ងាត់ទៀត ។ សម្តេចនរោត្តម សីហនុ បានយាងទៅធ្វើទស្សនៈកិច្ចនៅប្រទេសទាំងពីរ នាពេលជាមួយគ្នា តែពុំបានដឹងថា ពួកកុម្មុយនិស្តខ្មែរ នៅទីនោះទេ ។

**៤ តុលា** : សម្ពោធសកលវិទ្យាកំពង់ចាម ។

**៨ តុលា** : សហភាពសូវៀត ពុំសប្បាយចិត្តនឹងសម្តេច សីហនុ មានចំណងមិត្តភាពយ៉ាងចិត្តស្និតជាមួយនឹងចិន បានលប់ចោលទស្សនៈកិច្ចសម្តេចនរោត្តម សីហនុ ទៅមូស្គូ ។

**១៥ តុលា** : ទ័ពអាមេរិកាំង វាយប្រហារលើបាធូ ខេត្តស្វាយរៀង បណ្តាលឱ្យស្លាប់ខ្មែរ៧នាក់ ។

**២៥ វិច្ឆិកា** : លោកឧត្តមសេនីយ៍ លន់ ណុល ទៅដល់ប៉េកាំង ក្នុងនាមជានាយអគ្គសេនាធិការ និងយោធពលខេមរៈភូមិន្ទ បានចុះហត្ថលេខាសម្ងាត់ជាមួយនាយអគ្គសេនាធិការកងទ័ពចិន ក្នុងកិច្ចព្រមព្រៀងវៀតណាម នៅតាមព្រំប្រទល់ដែន និងការអនុញ្ញាតិឱ្យដឹកសម្ភារៈចិន ឆ្លងកាត់កម្ពុជា ទៅឱ្យយៀកណាមបាន ។ កិច្ចព្រមព្រៀងនៅបានធ្វើឱ្យកម្ពុជា បាត់បង់សិទ្ធិស្របច្បាប់ជាប្រទេសអព្យាក្រឹតទៅហើយ ។ កិច្ចព្រមព្រៀងសម្ងាត់រវាងសម្តេច សីហនុ និង ចិន នៅពេលនោះបានអនុញ្ញាត្តិឱ្យយោធាខ្មែរ កាត់យកជំនួយឆ្លងតាមកំពង់ផែក្រុងព្រះសីហនុ ចំនួន ១០% ។

(នៅមានត)

mann Since 1909
Funeral Home, INC.
219 West Tabor Road .
Philadelphia, PA 19120
(215) 458-3282
Henry S. Mann 1915-1993 | H.Craig Mann Supervesor | Frederick mann, Jr. Founder
A CENTURY of Excellence to the Delaware Valley
Proudly serving Asian Communities for over 48 years.
ឈាបនដ្ឋាន
"ម៉េន"
➩ បម្រើសហគមនតាំងព១០០ឆ្នាំមកហើយ មានទីកន្លែងសមរម្យធ្វើពិធីតម្កល់សព ។
➩ មានក្តារមឈូសអាចបូជា ឬបញ្ចុះសព នៅ ២០ឆ្នាំចុងក្រោយនេះ យើងមានសេវាបម្រើសហគមន៍ខ្មែរ ឱ្យអាចធ្វើបុណ្យតាមប្រពៃណី ជូនដំណើរអ្នកដែលបានចែកឋានទៅ ។
បើសិនមានសំណួរ សូមទាក់ទងទៅ :
Craig MANN : (215) 548-3292

# ពុទ្ធប្បវត្តិអមដោយរូបភាព

## A Pictorrial Biography of Saky amuni Buddha

ដោយ : អ៊ុម ល្មឿម

(តពីលេខមុន)



❖រូបភាព និងរឿងដើមជាភាសាថៃដោយ គុណាប៉ាយុតា

❖បកប្រែជាភាសាចិន ដោយ ភិក្ខុ ជែន ហាយ

❖បកប្រែជាភាសាអង់គ្លេស ដោយ ហ្សឺត .អេ.លី

❖ផាត់ពណ៌ដោយ យ៉ាន់ហ្វាលី

❖បកប្រែជាភាសាខ្មែរ ដោយភិក្ខុ គង់ អាំ

❖Original Illuatration and Naration in Thai by Gunapayuta.

❖Translation into Chinese by Bhikkhu Jan Hai.

❖Translation into English by Z.A Lu.

❖ Coloring by Yann-Fang Lee

❖Translation into Khmer by Bhikkhu Kong Am.

**១៤**-បន្ទាប់ពីព្រះនាងមហាទេវីសោយទីវង្គត់ទៅ ព្រះបាទសុទ្ធោទនៈ ទ្រង់បានតែងតាំងស្រីស្នំម្នាក់ទៀត គឺព្រះនាង **មហាបជាបតី** ដែលជាព្រះមាតុច្ឆា (ម្តាយមីង) របស់ព្រះរាជកុមារមានភារកិច្ចក្នុងការចិញ្ចឹមបីបាច់ព្រះអង្គម្ចាស់ ។ ព្រះនាងចិញ្ចឹមថែរក្សាបីបមថ្នាក់ថ្នមព្រះរាជកុមារដោយសេចក្តីស្រឡាញ់ក្រៃលែងដូចបុត្ររបស់ព្រះនាងបង្កើត ។



**14-** After queen Maya passed away, King Suddhodana entrusted another concubine with the task of taking care of the baby prince, Maha Praja Pati, Prince Siddharta's aunt. She took care of the prince and brought him up with as mush devotion as she would have shown to her own son. Thus prince Siddharta never really knew his own mother.

១៥-ក្រោមការបីបមថ្នាក់ថ្នមថៃដ៏អស់ពីចិត្តនៃព្រះមាតុច្ឆាមហាបជាបតិ ព្រះអង្គម្ចាស់រាជកុមារទ្រង់មានវ័យវឌ្ឍនាការចំរើនឡើងបន្តិចម្តង១ជាលំដាប់ ។ ព្រះអង្គទ្រង់មានព្រះរូបព្រះឆោមស្រស់សង្ហារក្រៃលែង និងទ្រង់មានព្រះសុខភាពល្អ ព្រមទាំងជាទីស្រឡាញ់ពេញចិត្តនៃជនទាំងពួង ។ នៅពេលដែលព្រះអង្គមានព្រះជន្ម៨វស្សា ព្រះមហាក្សត្រទ្រង់បានអញ្ជើញគ្រូដ៏ជំនាញ១ឱ្យមកកាន់ព្រះបរមរាជវាំង ដើម្បីបង្រៀនព្រះរាជបុត្រនូវការអានអក្សរ ការនិពន្ធ គណិត-វិទ្យា វិជ្ជាបាញ់ធ្នូ និងសិល្បវិធីផ្សេង១ទៀត ។



15- Under the careful eye of his aunt, Maha Prajapati, the prince gradually grew up. He was very handsome and healthy, a perfect darling to everyone . When he was eight-year old, the king began to invite all kinds of masters to the palace to educate him in the skills of reading, composition, mathematics, archery and other arts.

១៦-ដោយសារគ្រូម្នាក់១របស់ព្រះអង្គសុទ្ធតែជាគ្រូដ៏ស្ទាត់ជំនាញក្នុងការបង្រៀន សុទ្ធត្ថរាជកុមារទ្រង់បញ្ចប់ការសិក្សារៀនសូត្របានដោយងាយ និងមានភាពប្រាកដប្រជាទៀតផង ។ នៅពេលដែលមានការរីកចំរើនឡើងនូវកិរិតព្រះហស្ថយ៉ាងលឿនគួរកត់សំគាល់មកកើ្តឈ្មោះរបស់ព្រះអង្គដែលមានលើព្រះអង្គម្ចាស់កុមារដទៃ១ទៀតនោះ បង្ហាញឱ្យឃើញកាន់តែច្បាស់ឡើង១ថែមទៀត ។ មនុស្សទាំងឡាយរួមទាំងគ្រូទាំងអស់ ព្រះបិតា និងព្រះមាតុច្ឆា មានភាពអស្ចារ្យក្នុងចិត្តខ្លាំងដោយឃើញព្រះសុទ្ធត្ថរៀនវិជ្ជានីមួយ១បានចេះចាំយ៉ាងងាយស្រួល ។ នៅពេលដែលគ្រូបង្ហាញ ឬពន្យល់នូវមុខជំនាញឬចំណេះដឹងអ្វីមួយ ព្រះរាជកុមារទ្រង់យល់ និងចងចាំបានភ្លាមមួយរំពេច ដោយមិនភ្លេចវិញសោះឡើយ ។

(នៅមានត)



16- Since veryone of his teachers was an expert in his field, Prince Siddhartha completed all his studies with ease and thorughriess. When speed of progress and level of accomplishment were considered, his superiority over all the other princes was apparent. People, including his teachers, father and aund, were really surprised to see that Prince Siddhartha really had no difficulty at all in learning anything. Once any skill or knowledge was demonstrated or expounded, he immediately understood, remembered and never forgot it.

(continue Issue After)

# សម រង្ស៊ី : អភ័យឯកសិទ្ធិនៃសភាអាចនឹងត្រូវដកចេញ

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល**

•••លោក សម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី ដែលជាមេបក្សប្រឆាំងនាំមុខគេក្នុងប្រទេស តែងទទួលរងនូវការឃាយី និងការគំរាមកំហែងជាបន្តបន្ទាប់ពីតុលាការ ព្រមទាំងអ្នកនយោបាយផ្សេងៗទៀត ដើម្បីឱ្យលោកស្ទើរតែទ័លច្រកម្តងៗ ។

នេះជាលើទី3ហើយ ដែលលោក សម រង្ស៊ី ត្រូវបានតុលាការបញ្ជូន សំនុំរឿងសុំសេចក្តីសំរេចពីប្រធានសភាដើម្បីដកអភ័យឯកសិទ្ធិពីតំណាងរាស្ត្ររូបនេះ ក្នុងបំណងសាកសួរស៊ើបអង្កេតសំនុំរឿងផ្តាប់ចិត្តមន្ត្រីមានអំណាចរបស់គណបក្សប្រជាជនកម្ពុជា ។

ប៉ុន្តែការស្នើសុំដកអភ័យឯក សិទ្ធិលោក សម រង្ស៊ី នេះ ត្រូវបានអង្គការស្រាវជ្រាវសិទ្ធិមនុស្សអន្តរជាតិ ធ្វើការរិះគន់ ហើយសុំឱ្យធ្វើការពិចារណាឱ្យបានម៉ត់ចត់។

ក្នុងការឃោសនាជ្រើសរើសតំណាងរាស្ត្រលើកទី4 ថ្ងៃទី27 កក្កដា 2008 លោក សម រង្ស៊ី បានធ្វើការចែកចាយឯកសាររបស់អង្គការ Global Withness ដែលទាក់ទងនឹងសែស្រឡាយអ្នកលក់ជាតិ ក្នុងឯកសារនោះ មានឈ្មោះ ហ៊ុន សែន និងភរិយាព្រមទាំងមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាច្រើននាក់ទៀតពីបទបំផ្លិចបំផ្លាញព្រៃឈើ និងធ្វើការរិះគន់ចំពោះអ្នកទាំងនោះខ្លាំងៗ ។

ជាប្រតិកម្មតបគណៈកម្មាធិការជាតិរៀបចំការ



ហ៊ុន សែន



លោក សម រង្ស៊ី



លោក ឡៅ ម៉ុងហៃ

បោះឆ្នោត ដែលស្ថិតនៅក្រោមអំណាចរបស់ ហ៊ុន សែន ក៏បានប្តឹងលោក សម រង្ស៊ី ពីបទរំលោភលើច្បាប់បោះឆ្នោត ដោយទារប្រាក់ចំនួន10លានរៀលស្មើនឹង2500ដុល្លារ ។ ប៉ុន្តែរឿងក្តីនេះបានអូសបន្លាយរហូតដល់សព្វថ្ងៃ ហើយតុលាការភ្នំពេញត្រូវបានគេមើលឃើញមិនឯករាជ្យ និងស្ថិតក្រោមឥទ្ធិពលនយោបាយ ក៏បានធ្វើលិខិតទៅរដ្ឋសភាដើម្បីសុំដកអភ័យឯកសិទ្ធិពីលោក សម រង្ស៊ី តែម្តង ។

លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាអ្នកនាំពាក្យរបស់រដ្ឋាភិបាលក៏បានបញ្ជាក់ថា ក្រសួងយុត្តិធមិបានជូនដំណឹងមក លោកថា មានលិខិតមួយច្បាប់ផ្ញើទៅរដ្ឋសភា ដើម្បីសុំដកអភ័យឯកសិទ្ធិពីលោក សម រង្ស៊ី។

លោក សុខ រឿន ព្រះរាជអាជ្ញារងក្រុងភ្នំពេញ ដែលកាន់ក្តីលោក សម រង្ស៊ី ខណៈពេលដែលអ្នកសារព័ត៌មានសុំការបំភ្លឺ ទាក់ទងនឹងករណីនេះបានបដិសេធមិនធ្វើអត្ថាធិប្បាយ ដោយចាត់ទុកថា នោះជារឿងសំងាត់មិនអាចប្រាប់ជាសាធារណៈបាននោះទេ ។ ការសុំដកអភ័យឯកសិទ្ធិពីតុលាការក្រុងភ្នំពេញនេះ គឺបន្ទាប់ពីលោក សុខ រឿន បានកោះហៅលោក សម រង្ស៊ី សាកសួរ និងបង្ខំឱ្យបង់លុយចំនួន 2500ដុល្លារទៅឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

លោក សម រង្ស៊ី ក៏បាន បញ្ជាក់ថា នឹងបង់ឱ្យតុលាការនៅពេលដែលអស់ជំរើសផ្លូវច្បាប់រួមទាំងតុលាការកំពូលទៀតផង ។

លោក ជាម យៀប សមាជិកសភាមកពីគណៈបក្សប្រជាជនកម្ពុជា ត្រូវបាន The Cambodia daily ស្រង់សំដីថា លោកមិនទាន់បានឃើញសំណើរបស់តុលាការសុំដកអភ័យឯកសិទ្ធិលោក សម រង្ស៊ី ទេ ហើយលោក សម រង្ស៊ី ត្រូវតែបង់លុយឱ្យគេបើខ្លាចកុំប្រព្រឹត្តល្មើស ។

(តទៅទំព័រទី២០)

BE IN THE MOVIE

A MAJOR MOTION PICTURE FILMING IN PHILADELPHIA

"THE LAST AIRBENDER"

មានរូបអ្នកក្នុងខ្សែភាពយន្ត ដែលថតនៅហ្វីឡាដែលហ្វីយ៉ា

ផលិតឡើងតាមលំនាំដែលធ្លាប់ទទួលជោគជ័យដ៏ត្រចះត្រចង់នៃបច្ចេកទេសរូបភាពមានចលនា នឹងភាពយន្ត រឿង THE LAST AIRBENDER ដឹកនាំសរសេរ និងផលិតដោយ Night CHYAMALAN បានកើតឡើងនៅក្នុងពិភពលោក ដែលអារិយធមិរបស់មនុស្ស ចែកចេញជាប្រជាជាតិបួន : ខ្យល់-ដី-ទឹក-ភ្លើង ។

*ផ្តើមថតហើយ : យើងត្រូវការសិល្បករក្បាច់គុនប្រដាល់-សិប្បករ-សិល្បករ-អ្នករបាំ-កីឡាពលករ-គ្រួសារ និងជីដូនជីតា ។*

*យើងរកខ្មែរ-អាមេរិកាំង : ស្រី,ប្រុស,ក្មេង,ចាស់ អាយុពី ៥ដល់ ៨៥ឆ្នាំ មិនចាំបាច់មានបទពិសោធន៍អ្វីទេ ។*

*បើ Cast ជាប់ : តួនាទីទាំងអស់សុទ្ធតែមានប្រាក់បៀវត្សរ៍ ហើយត្រូវទំនេរ ពីថ្ងៃទី ០៩ មីនា ដល់ ថ្ងៃ ០៩ កក្កដា ឆ្នាំ ២០០៩ ។*

សូមទូរស័ព្ទមកការិយាល័យរបស់យើង 215-226 1939 ដើម្បីណាត់ជួបគ្នារហូតដល់ថ្ងៃទី២០ មីនា២០០៩ -សូមស្លៀកពាក់ធម្មតា ឬតាមប្រពៃណីនៃគ្រួសារអាណិកជន-យើងថតរូបជូន នឹងទទួលព័ត៌មានពីលោកអ្នក ។

លោកអ្នកអាចអ៊ីមែលមក : Lastairbender@gmail.com

ដោយភ្ជាប់រូបថត ដាក់ឈ្មោះ លេខទូរស័ព្ទ និងអាយុជាមួយផង ។

ចង់ដឹងព័ត៌មានផ្សេងៗទៀត សូមទូរស័ព្ទ: 215-574 7878

ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេក្នុងលោក គឺទឹកផ្លែឈើ "គោជី" នៃព្រៃហេមពាន្ត

HIMALYAN GOJI Juice







ការសម្ងាត់នៃសុខភាពល្អរបស់ពួកអាស៊ីបានត្រូវរកឃើញ នារជ្ជកាលស្តេចតាំង ឆ្នាំ ៨០០ គ.ស ពលរដ្ឋនៃតំបន់មួយនៅព្រៃហេមពាន្តមិនព្រមចាស់-សក់ក៏មិនស-ធ្មេញក៏មិនបាក់-គេថា អ្នកស្រុកបានផឹកទឹកអណ្តូងមួយដែលមានដើម "គោជី " ដុះជុំវិញ គេស្មានថា មានវត្ថុសក្តិសិទ្ធអ្វីមួយជួយថែរក្សាពួកគេ ។ ទើបតឡូវនេះ គេដឹកថា "គោជី " មានជីវជាតិពិសេសមួយ ឈ្មោះ POLYSACHARIDES ដែលពុំមាននៅផ្លែឈើឯណាទៀតសោះ ដែលជួយដល់ប្រព័ន្ធការពារខ្លួនរបស់មនុស្សបាន ។

SHARE THE SECRET

បើចង់បាន Goji មកពិសារសូមជាវតាម www.forever.freelife.com

ឬទូរស័ព្ទលេខ : (267) 253-3947

## (តមកទៅទំព័រទី១៤) ទាហាន លន់ នល់ អាចទទួល...

នោះត្រូវបានមនុស្សស្រីម្នាក់លើកដៃលម្តងថា អត់នៅ ដែលម្តងទៀតថាអត់ស្គាល់ ប្រហែលជាច្រឡំលេខទូរស័ព្ទទេដឹង ! ។

លោក ទូច សម្បត្តិ ត្រូវបានគេស្គាល់ម្តងកាលនៅក្នុងពិធីដង្ហែក្បួនព្យូហ៍យាត្រាអបអរសាទរបុណ្យចូលឆ្នាំខ្មែរនៅតាមដងផ្លូវ Anaheim ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលគេឃើញរូបលោកមានឯកសណ្ឋានជាយោធាពាក់សក្តិ 5 ទៀតផង ដោយគេគិតថា រូបលោកចង់បង្ហាញឱ្យអ្នកកំសាន្តតាមដងផ្លូវបានឃើញ និងនឹកគិតទៅរកអតីតកាលក្នុងរបបសាធារណរដ្ឋខ្មែរនាទសវត្សរ៍ឆ្នាំ 70 ចំពោះអ្នកដែលបានឆ្លងកាត់នាអំឡុងកាលនោះ ។

អតីតកងទ័ពពិសេសក្នុងជំនាន់ លន់ នល់ លោក ប៉ែន សិរិត បាននិយាយថា បញ្ហានេះវាជារឿងបោកប្រាស់ហើយ ដោយសហរដ្ឋអាមេរិកគ្មានគោលនយោបាយណាមួយសំរាប់ផ្តល់ជាប្រាក់ខែ ឬប្រាក់ឧបត្ថម្ភជូនដល់អតីតយុទ្ធជនខ្មែរក្នុងរបបសាធារណរដ្ឋទេ ។ យើងបានឮដំណឹងនេះពីមិត្តភក្តិគ្រប់ទិសទីនៅជុំជិតមាននៅទីក្រុង Long Beach, Mongterey-Park, El Monte, Stockton និង Monesto ជាដើម ដែលលោក ទូច សម្បត្តិ អះអាងថា ខ្លួនជាសក្តិ5 សម័យ លន់ នល់ នោះ កំពុងតែដើរឃោសនាឱ្យគេបំពេញបែបបទ ដោយមានលេខសន្តិសុខ-សង្គម (S.S.N)ទៀតផង ដោយយកលុយកាក់ម្នាក់ៗចំនួន375ដុល្លារ ។

លោក ប៉ែន សិរិត បានបន្តថា សមាគមអតីតយុទ្ធជនដែលគេកកើតតាមផ្លូវច្បាប់អាមេរិកត្រឹមត្រូវមកជាង30ឆ្នាំហើយនោះ ម្តេចពួកគេមិនដឹងពីបញ្ហានេះ ? ដែលពួកគេមានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលអាមេរិកពិសេសក្រសួងការពារជាតិអាមេរិក ។ បើរឿងនេះជាការពិតម្ល៉េះក្រសួងការពារជាតិអាមេរិកគេទំនាក់ទំនងមកសមាគមអតីតយុទ្ធជនមួយនេះបាត់ទៅហើយ ។

អតីតវរសេនីយ៍ត្រីបើកយន្តហោះចម្បាំង លោក គង់ ឆាយហុង ដែលធ្លាប់ធ្វើចម្បាំងតាមយន្តហោះជាមួយពួកយួនយៀកកុង និងក្រុមឧទ្ទាមខ្មែរក្រហមតាំងពីឆ្នាំ 1971 រហូតមកដល់ស្រុកធ្លាក់មានសង្គ្រាម ដែលរូបលោកបានត្រូវខ្មាំងបាញ់ទម្លាក់4ដងនៅតែមានជីវិតរស់រានបានប្រាប់ខ្មែរប៉ុស្តិ៍ថា ទង្វើដែលមានអ្នកអះអាងថា បំពេញបែបបទទទួលប្រាក់ខែ និងប្រាក់ឧបត្ថម្ភពីអាមេរិកនោះវាគ្មានទេ ពួកគេកំពុងតែបោកប្រាស់បងប្អូនហើយ ព្រោះទ័ពសាធារណរដ្ឋមិនមែនជាទ័ពអាមេរិកាំងទេ សូមកុំយល់ច្រឡំ វាគ្រាន់តែជាកិច្ចប្រតិបត្តិការយោធាសឹកច្បាំងជាមួយសត្រូវយួនខាងជើង និងពួកខ្មែរក្រហមតែប៉ុណ្ណោះ ។ វាផ្ទុយពីយួនខាងត្បូងមួយចំនួនដែលអាមេរិកាំងជ្រើសរើសក្នុងក្របខ័ណ្ឌទ័ពអាមេរិកក្នុងសម័យសង្គ្រាមនៅវៀតណាមឆ្នាំ 1968-1970 ទើបអាចទទួលប្រាក់ខែរបស់គេបាន ។ ប៉ុន្តែសំរាប់ស្រុកខ្មែរនាសម័យ លន់ នល់ នោះ គ្មានខ្មែរឯណាត្រូវបានជ្រើសរើសចូលធ្វើជាកងទ័ព តាមក្របខ័ណ្ឌត្រឹមត្រូវទេ ។

ប្រធានសមាគមអតីតយុទ្ធជនលោក លី កាល់មីន ដែលជាអតីតកងទ័ពអាកាសពាក់សក្តិ3ក្នុងរបបសាធារណរដ្ឋខ្មែរ បានប្រាប់ខ្មែរប៉ុស្តិ៍ឱ្យដឹងថា យើងមិនបានដឹងឮពីបញ្ហានេះទេ ថាតើពិត ឬជាការបោកប្រាស់ទេ ព្រោះតាមគាត់ដឹង គឺគ្មានគោលការណ៍ផ្តល់ប្រាក់ខែ ឬប្រាក់ឧបត្ថម្ភអ្វីពីអាមេរិកឱ្យក្រុមកងទ័ពខ្មែរដែលជាអតីតទាហាន លន់ នល់ នោះទេ ព្រោះទាហាន លន់ នល់ មិនមែនជាទាហានអាមេរិកទេ ។ វាទាល់តែខ្មែរណាដែលចូលជាទ័ពអាមេរិកមានអត្តលេខជាក្របខ័ណ្ឌទាហានអាមេរិកទើបអាចមានការជួយជាប្រាក់បៀវត្សរ៍ ឬជាប្រាក់បំណាច់ ។ បញ្ហានេះក្នុងនាមជាសមាគមអតីតយុទ្ធជន យើងសូមបដិសេធប្រសិនបើមានករណីអ្វីដែលប៉ះពាល់ដល់កិត្តិយសសមាគមអតីតយុទ្ធជនដែលជាការមិនអាចទទួលយកបាន ។

អនុសេនីយ៍ឯក លី កាល់មីន បន្តថា គាត់មិនបានស្គាល់អត្តសញ្ញាណនៃមនុស្សដែលដើរធ្វើបញ្ហានេះទេ ។ ប៉ុន្តែសំរាប់អតីតទាហានដូចគ្នាមានក្របខ័ណ្ឌចេញពីសាលារៀនហ្វឹកហាត់ត្រឹមត្រូវ មានការទាក់ទងស្គាល់គ្នា និងពិគ្រោះយោបល់គ្នាបានល្អណាស់មុននឹងសម្រេចធ្វើកិច្ចការងារអ្វីមួយ ។ ពួកយើងមានឋានន្តរ-សក្តិត្រឹមត្រូវ គឺស្ថិតក្នុងសេចក្តីថ្លៃថ្នូរ និងការគោរពវិន័យខ្ជាប់ខ្ជួនតាំងពីសម័យសាធារណរដ្ឋខ្មែរ រហូតមកដល់សព្វថ្ងៃ គឺមិនធ្វើអ្វីដែលផ្តេសផ្តាសខុសច្បាប់ទម្លាប់ ដើរបោកប្រាស់គេឯងនោះទេ ។ ព្រោះទាហានដែលមានសក្តិពាក់ត្រឹមត្រូវមិនដែលអួតអាង ផ្ទុយពីទាហានតាមតៀមស្រា Sic ។

ខ្មែរប៉ុស្តិ៍ពុំទាន់មានការឆ្លើយតបតាមសារអ៊ីមែលណាមួយមកវិញនៅឡើយទេ ពីនាយកដ្ឋានកិច្ចការបរទេសនៃក្រសួងការពារជាតិមកដល់ថ្ងៃនេះ ជុំវិញការសាកសួរទាក់ទងទៅនឹងករណីដែលថា អតីតទាហាន លន់ នល់ អាចនឹងទទួលបានប្រាក់ខែពីរដ្ឋាភិបាលអាមេរិកាំងនោះទេ ៕

**មាជ សុវណ្ណារ៉ា**

From :Philadelphia



សួស្តីឆ្នាំថ្មី

ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

**Rathe`s Auto Service**




State and Emission
Inspection General
Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨
ទៅ : -ដូរប្រេងគិត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

**ANGKOR AUTO SERVICE, INC.**

ហាងជួសជុលរថយន្ត "អង្គរ"

4835 N. 16th Street. Tel : (215) 455-7810
Philadelphia, Pa 19141 Ricky : (215) 485-1425

Specializing in Body Kit and Custom Paint

ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425




មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្តមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អ៊ីនស្វីរ៉ង់ បានផង
យើងផ្តល់សេវាគ្រប់យ៉ាង :
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C



បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍

ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ

(តមកនៅទំព័រទី០១) ## ខ្មែរហ្វីឡាចូលថតកុនហូលីវូត...

ក៏បានទៅចុះឈ្មោះ កាលពីថ្ងៃសុក្រ ទី៦ មីនា ហើយថតរូបជាឯកសារជាមួយបុគ្គលិកផលិតកម្មមកពីហូលីវូត ដោយសង្ឃឹមថា ខ្លួនម្នាក់ៗនឹងមានតួនាទីក្នុងរឿង " THE LAST AIR-BENDER " ជាមិនខាន ។

ដឹកនាំរឿងដោយ Night Shyamalan ដ៏មានឈ្មោះល្បី ខ្សែភាពយន្តនេះនឹងត្រូវការអ្នកសំដែងជាច្រើនអ្នកទៀត ដែលមានលក្ខណៈសម្បត្តិស្របទៅនឹងសាច់រឿង គេត្រូវការខ្មែរ-ឡាវ-ម៉ុងគ្គោលី និងជប៉ុន ឱ្យទទួលការជ្រើសរើស ដោយកំពុងប្រព្រឹត្តទៅយ៉ាងសកម្មនាពេលនេះ នៅហ្វីឡាដែលហ្វីយ៉ា ។

"THE LAST AIRBENDER" គឺជារឿងសិប្បនិមិត្ត និយាយអំពីអវកាស ធាតុធម្មជាតិទាំងបួន មាន ខ្យល់-ទឹក-ដី-ភ្លើង ដែលឱ្យកំណើតដល់ពិភពលោកយើង ។ ធាតុទាំងបួននេះ តែមានវាសនានៅជាប់ជាមួយគ្នាជារហូតមកដល់ពេកមួយនោះ ជាតិភ្លើងបានសម្រេចចិត្តធ្វើសង្គ្រាមយ៉ាងសាហាវប្រឆាំងនឹងជាតិផ្សេងៗទៀត ។ ជារឿងដែលពោរពេញទៅដោយការប្រយុទ្ធ និងបង្ហាញសេចក្តីក្លាហាន មានឥទ្ធិពលអាចប្រើធាតុផ្សេងៗ តែទោះជាខ្លាំងយ៉ាងណាក៏ដោយ ជាតិភ្លើងត្រូវប្រយុទ្ធដើម្បីរក្សាជីវិតខ្លួនឯង ពីព្រោះជាធម្មជាតិដែលមិនអាចរស់តែម្នាក់ឯងបាន ។

រឿងសិប្បនិមិត្តលក្ខណៈវិទ្យាសាស្ត្រនេះ សរសេរ ដឹកនាំរឿង និងសំដែងដោយ Night Shyamalan ដែលធ្លាប់ទទួលបានការស្នើឈ្មោះរង្វាន់ " អូស្កា " ពីរដង និងឈ្នះពាន់រង្វាន់ពីសិល្បៈភាពយន្តនេះ ៩ដង រឿងកុនដ៏ល្បីល្បាញរបស់លោក ដូចជា Sings (2002) THE SIXTH SENSE (1999) ។ លោកជាជនជាតិកំណើតឥណ្ឌា ធ្លាប់រស់នៅរដ្ឋ ផែនស៊ីវែនញ៉ា នៅតំបន់ផិនវ៉ាឡេ ដែលកំពុងផ្តល់ឱកាសឱ្យខ្មែរ នៅហ្វីឡាដែលហ្វីយ៉ា ជាលើកដំបូងបង្អស់ឱ្យបានស្គាល់រស់ជាតិជាតួសំដែងឱ្យភាពយន្តហូលីវូតដ៏អស្ចារ្យ ដ៏រំភើបនាពេលនេះ ។

**ពិន សំខុន**







ឱសថស្ថានខ្មែរ
Sav-Mor PHARMACY
Tel: 215-467-1220
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447

បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត

- Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
- យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ

*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

ក្រុមហ៊ុន ទេសចរណ៍
CENTURY TRAVEL & SERVICE CENTER
904 South 8th Street. Philadelphia, Pa 19147
Tel. 215.625.2889 – Fax. 215.625.9395
Cell: 267.934.9888 – email: centuryphl@yahoo.com

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនិងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ធ្វើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

OFFICE Hours :
Mon - Sat 10:00 A.M - 6:00 P.M
Sun : 12:00 P.M - 5:00 P.M
Serve all Airlines
National & International flights
Khmer Passport Extension
Immigration
Tourist Visa
Money Transfer
Notary Public

We speak Khmer, Chinese Vietnamese
យើងនិយាយភាសាខ្មែរ_ភាសាចិន វៀតណាម

NEW YORK LIFE
អត់ពីលោកអ្នកទៅ តើបាននរណាជួយថែរក្សាកូនចៅលោកអ្នក ?

១-ទិញការធានារ៉ាប់រងសម្រាប់ជីវិត (Life Insurance)
២-សន្សំលុយសំរាប់ចូលនិវត្តន៍ (Retirement Planning)
៣-សន្សំលុយសម្រាប់កូនចូលរៀនមហាវិទ្យាល័យ (College Saving)
៤-រៀបចំទ្រព្យសម្បត្តិទុកឱ្យកូនចៅ (Estate Planning)


WUTHA CHIN MBA, Agent New York Life

ខ្ញុំអាចជួយពន្យល់ដល់បងប្អូនដោយមិនយកកម្រៃ
P. (610) 660 5897, Cell. P (267) 736 0445
wchin@ft.newyorklife.com

(តមកពីទំព័រទី១៥)

# សម រង្ស៊ី : អភ័យឯកសិទ្ធិនៃ...

លោក ជាម យៀប បន្តថា សភាជាតិត្រូវតែដកអភ័យឯកសិទ្ធិលោក សម រង្ស៊ី ដើម្បីឱ្យគាត់បង់ប្រាក់តាមច្បាប់ ។

ចំណែកលោក សម រង្ស៊ី ក៏បានឱ្យដឹងថា លោកមិនបារម្ភអំពីព័ត៌មាននៃការស្វះស្វែងរបស់តុលាការដកអភ័យឯកសិទ្ធិសភានោះទេ អ្វីដែលសំខាន់គឺសម័យប្រជុំសភាមានតំលៃជាងការពិន័យរបស់ខ្ញុំខ្លាំងណាស់ ។

លោក សម រង្ស៊ី បញ្ជាក់ថា លោកនឹងបង់លុយឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រសិនបើគេទាមទារខ្លាំង ហើយស៊ូក្រាញនន្ទៀលលើផ្លូវច្បាប់ចប់សព្វគ្រប់សិន ។

ទាក់ទងទៅនឹងការព្យាយាមដកអភ័យឯកសិទ្ធិលោក សម រង្ស៊ី នេះ លោក ឡៅ ម៉ុងហៃ អ្នកស្រាវជ្រាវសិទ្ធិមនុស្សជាន់ខ្ពស់នៅអាស៊ី ធ្លាប់បានធ្វើការរិះគន់ចំពោះសភាជាតិថា សភាជាតិគួរតែធ្វើការពិចារណា និងការពារកូនចៅរបស់ ខ្លួនមិនត្រូវធ្វើអ្វីតាមការស្នើសុំរបស់ស្ថាប័នតុលាការនោះទេ កុំអាងពីដកអភ័យឯកសិទ្ធិដែលគេមើលទៅដូចជាមិនយុត្តិធម៌ ។

នៅពេលថ្មីៗនេះ តំណាងរាស្ត្រគណបក្ស សម រង្ស៊ី ចំនួន18រូប បានសរសេរលិខិតទៅក្រុមប្រឹក្សាធម្មនុញ្ញឱ្យពិនិត្យករណីដកអភ័យឯកសិទ្ធិលោក សម រង្ស៊ី និងស្នើសុំឱ្យប្រធាន សភាលោក ហេង សំរិន ផ្អាកមួយរយៈសិន ។

ប៉ុន្តែលោក ជាម យៀប បានបញ្ជាក់ថា សភាត្រូវតែដំណើរការរបស់ខ្លួនឱ្យបានឆាប់តាមអ្វីដែលអាចធ្វើទៅបាន ។

ការសុំដកអភ័យឯកសិទ្ធិពីប្រធានគណបក្សប្រឆាំងនេះត្រូវអ្នកវិភាគខ្លះយល់ថា ជារឿងបក្សពួក និងហេតុផលនយោបាយ ដោយសារតែការបោះឆ្នោតក្រុមប្រឹក្សាស្រុក-ខេត្ត និង ខណ្ឌ-ក្រុងជិតមកដល់ ហើយគណបក្សប្រឆាំងទាំងពីរកំពុងរួមគ្នាចងច្របាច់ ដើម្បីដណ្ដើមយកជ័យជំនះ ។

កាលពីថ្មីៗនេះ ហ៊ុន សែន បានព្រមានជាសាធារណជនថា សម រង្ស៊ី ត្រូវតែបង់លុយឱ្យ គ.ជ.ប បើពុំនោះ ទេនឹងត្រូវដកអភ័យឯកសិទ្ធិសំរាប់សម្លេង2/3មិនពិបាករកទេ ។

ច្បាប់នៅស្រុកខ្មែរ កាលណាអ្នកមានអំណាចនិយាយអ្វីហើយ មិនយូរមិនឆាប់ប្រាកដជាអនុវត្តតាម គឺពុំបានយករដ្ឋធម្មនុញ្ញមកពិនិត្យ និងដោះស្រាយឡើយ ។

គួរបញ្ជាក់ថា កាលពីខែកុម្ភៈ ឆ្នាំ2005 លោក សម រង្ស៊ី ត្រូវបានសភាដកអភ័យឯកសិទ្ធិករណីបង្ខូចកេរ្តិ៍ឈ្មោះព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ។ នៅខែសីហា ឆ្នាំ2008 ត្រូវបានតុលាការក្រុងភ្នំពេញស្នើឱ្យដកអភ័យឯកសិទ្ធិម្ដងដែរ ករណីបណ្ដឹងរបស់លោក ហោ ណាំហុង បង្ខូចកេរ្តិ៍ ឈ្មោះ និងផ្សាយព័ត៌មានមិនពិតដែលកាលនោះ លោក ដាំ សិទ្ធិ ចាងហ្វាងកាសែតមនសិការខ្មែរ ត្រូវគេចាប់ដាក់គុកព្រៃស ដោយតុលាការក្រុងភ្នំពេញ ៕

ចាន់ កុសល




